# ជីវប្រវត្តិសង្ខេប
# របស់ព្យាការីមូហាំម៉ាត់

# مختصر السيرة النبوية

## មាតិកាអត្ថបទ                                ទំព័រ


១- សេចក្ដីផ្ដើម ..........................................02
២- ភាពឧត្ដុងឧត្ដមរបស់បណ្ដាណាប៊្ី ..........................06

ជំពូកទី១

៣- ត្រកូលឧត្ដុងឧត្ដម ..........................................0៩
៤- កំណើតរបស់ណាប៊្ី មូហាំម៉ាត់..................................១៦

ជំពូកទី២

៥- ការក្លាយខ្លួនជាណាប៊្ី និងការអំពាវនាវ ..........................២៧
៦- ប្រភេទនៃការបញ្ចុះវ៉ាហ៊ុី ..........................................២៨
៧- បេសកកម្មនៃការអំពាវនាវ .......................................... ៣២
៨- ផែនការកំទេចកំណត់ត្រាបោកប្រាស់ .............................. ៤១
៩- ឆ្នាំក្រៀមក្រំបំផុត .................................................. ៤៤
១០- ដំណើរអ៊ីសរ៉ក និងមៀករ៉ាច ...................................... ៤៨

ជំពូកទី៣

១១- ការផ្លាស់ទីលំនៅរបស់ណាប៊្ី .......................................... ៥៨
១១- កិច្ចការនិងការកសាងនៅម៉ាឌីណះ.................................. ៦0
១២- សមរភូមិសំខាន់ៗមួយចំនួន .......................................... ៦២
១៣- មរណះភាពរបស់ណាប៊្ី .............................................. ៦៧
១៤- ក្រុមគ្រួសាររបស់ណាប៊្ី ............................................ ៦៨




**بسم الله الرحمن الرحيم**

الحمدلله رب العالمين والصلاة والسلام على نبينا محمد وسلم تسليما كثيرا .. أما بعد :

មិត្តអ្នកអានទាំងឡាយ!នេះជាកម្រងអត្ថបទថ្មីមួយទៀតដែលក្រុមយើងខ្ញុំរៀបរៀងនិងប្រែសំរួលជាខេមរៈភាសា។ ដោយយល់ឃើញថាវាមានតំរូវការចាំបាច់ចំពោះចំណេះដឹងដែលពាក់ព័ន្ធប្រវត្តិរបស់ណាប៊្ីﷺក្រុមយើងខ្ញុំបានដកស្រង់ពីសៀវភៅមួយចំនួននិងបានសំរួលជាខេមរៈភាសា។ សៀវភៅនេះមានចំណងជើងថាៈ " **ជីវប្រវត្តិសង្ខេបរបស់ណាប៊្ីមូហាំម៉ាត់ﷺ** " ។

នៅក្នុងអត្ថបទនេះដែរយើងខ្ញុំបានសរសេរជាលក្ខណៈសង្ខេបផ្ដោតលើចំនុចចំបងៗនិងលើកបង្ហាញពីអត្ថប្រយោជន៍មួយចំនួនក្នុងការសិក្សាស្វែងយល់ពីប្រវត្តិរបស់ណាប៊្ីមូហាំម៉ាត់ ។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះពិតជានឹងផ្ដល់ចំណេះដឹង និងអត្ថប្រយោជន៍ដល់បងប្អូនមិត្តអ្នកអានក្នុងការស្វែងយល់អំពីអ៊ីស្លាម និងអាចឈានទៅអានសៀវភៅដែលមានទំរង់ធំៗជាងនេះបានងាយយល់ ងាយចាំទៀតផង ។

យើងខ្ញុំរង់ចាំនូវរាល់ការរិះគន់ស្ថាបនាដោយរីករាយពីសំណាក់បងប្អូនមិត្តអ្នកអានគ្រប់ពេល។ សូមបួងសួងពីអល់ឡោះសូមទ្រង់បំភ្លឺនិងចង្អុលបង្ហាញដល់ក្រុមយើងខ្ញុំ និងមិត្តអ្នកអានទៅរកមាគ៌ាដ៏ត្រឹមត្រូវក្នុងលោកនិងបរលោក។

# ជីវប្រវត្តិសង្ខេបណាហ្គីមូហាំម៉ាត់ ﷺ

**សេចក្តីផ្តើម :**

តំរូវការចាំបាច់របស់មនុស្សក្នុងការស្វែងយល់ពីជីវប្រវត្តិរបស់ណាហ្គី[១] ដែលអល់ឡោះជាម្ចាស់ដ៏ឧត្តុងឧត្តមទ្រង់ចង់បង្កើតឬជ្រើសរើសតែងតាំងអ្វីឬបុគ្គលណាមួយតាមបំណងប្រាថ្នារបស់ទ្រង់ ។ការជ្រើសរើសតែងតាំងនេះចង់បង្ហាញពីឧត្តមភាពក្នុងការគ្រប់គ្រង និងភាពតែមួយរបស់ទ្រង់ពោរពេញទៅដោយគតិបណ្ឌិត ។

ពិតណាស់អល់ឡោះបានតែងតាំងបណ្តាណាហ្គីពីកូនចៅអាឌាំប្រមាណ ១២៤.000នាក់ហើយក្នុងនោះបានតែងតាំង៣១៣នាក់ ជារ៉ស៊ូល[២] ផងដែរ ។

អល់ឡោះបានបញ្ជាក់នៅក្នុងគម្ពីរអាល់គួរអាននូវរ៉ស៊ូលនិងណាហ្គីចំនួន ២៥រូប ។ក្នុងចំណោមរ៉ស៊ូលទាំងនោះទ្រង់បានជ្រើសរើស និងតែងតាំងរ៉ស៊ូល៥រូបដែលជាអ្នកមានឧត្តមភាពជាងគេ ។ លោកទាំងប្រាំនោះគឺ ណួហ៍ អ៊ីបរ៉ហ៊ីម មូសា អ៊ីសា និងមូហាំម៉ាត់ ។នៅក្នុងចំណោមទាំង៥រូបនេះទៀត ទ្រង់បានផ្តល់ឋានៈជាខលីល[៣]២រូបក្នុងនោះគឺអ៊ីបរ៉ហ៊ីមនិងមូហាំម៉ាត់ ។ក្នុងចំណោមខលីលទាំងពីរនោះទ្រង់បានផ្តល់តួនាទីនិងតែងតាំងជាចៅហ្វាយទៅលើបណ្តាកូនចៅអាឌាំទាំងអស់ផងដែរ ។

---

*១ - ណាហ្គី :ព្យាការីរបស់អល់ឡោះដែលទ្រង់បានជ្រើសតាំងមកដឹកនាំមនុស្សលោកទៅកាន់មាគ៌ារបស់ទ្រង់ក្នុងកិច្ចគោរពប្រតិបត្តិដោយអនុវត្តតាមក្រិត្យច្បាប់សាហារីមុនៗដែលទ្រង់បានផ្តល់ ។*

*២-រ៉ស៊ូល :សាហារី របស់អល់ឡោះដែលទ្រង់តែងតាំងដោយផ្តល់នូវច្បាប់សំរាប់អប់រំនិងដឹកនាំមនុស្សលោកដើម្បីគោរពប្រតិបត្តចំពោះទ្រង់តែមួយ ។*

*៣-ខលីល : អ្នកជំនិតដែលជាទីស្រលាញ់របស់អល់ឡោះ ។*



ពិតណាស់ចំពោះបណ្តាជនអ្នកមានជំនឿទាំងឡាយត្រូវតែយល់ដឹងអំពីជីវប្រវត្តិរបស់រ៉ស៊ូលមូហាំម៉ាត់ ពីព្រោះថាគ្មានមធ្យោបាយណាដែលនាំអោយបុគ្គលម្នាក់ទទួលបានជោគជ័យ និងសុភមង្គលនៅក្នុងលោកីយ៍ និងបរលោកក្រៅពីមានជំនឿចំពោះរ៉ស៊ូលនូវអ្វីដែលលោកបានផ្តល់និងគោរពប្រតិបត្តិតាមអ្វីដែលលោកបានបង្គាប់ប្រើ ព្រមទាំងជៀសវាង និងបោះបង់ពីអ្វីដែលលោកបានហាមឃាត់ ។

**ហេតុអ្វីបានជាយើងគោរពស្រលាញ់រ៉ស៊ូលមូហាំម៉ាត់ ﷺ ?**

យើងគោរព ស្រលាញ់ និងចូលចិត្តរ៉ស៊ូលមូហាំម៉ាត់ពីព្រោះ :

- លោកគឺជារ៉ស៊ូលម្នាក់ក្នុងចំណោមបណ្តារ៉ស៊ូលដែលអល់ឡោះបានតែងតាំងនិងបញ្ជូនមកសំរាប់មនុស្សលោកទូទៅ ។
- លោកជាមនុស្សទន់ភ្លន់ សុភាពរាបសារពោរពេញដោយក្រមសីលធម៌ មានគុណធម៌ និងសច្ចៈធម៌ ។
- លោកមិនបង្ខិតបង្ខំបុគ្គលណាម្នាក់ឱ្យប្រកាន់យកសាសនាអ៊ីស្លាមឡើយ តែលោកបានពន្យល់បកស្រាយបង្ហាញរាល់ភស្តុតាងដែលនាំឱ្យគេអាចទទួលយកបាន ។
- លោកជាអ្នកមានថ្វីមាត់ក្នុងការនិយាយស្តី ពោលគឺប្រើពាក្យសំដីល្អៗក្នុងការផ្សព្វផ្សាយសាសនាអ៊ីស្លាមនិងការអប់រំផ្សេងៗ ។
- លោកជាកូនកំព្រាឳពុក មានប្រាជ្ញាស្មារតីពេញលេញ ជាអ្នកទទួលនូវការផ្តល់និងការជ្រើសរើសពីអល់ឡោះ ។

## មូលហេតុនិងគោលបំណង ដែលនាំឱ្យជនមូស្លីម យកចិត្តទុកដាក់ចំពោះជីវប្រវត្តិ របស់ណាហ្ពីមូហាំម៉ាត់ﷺ:

- វាជាច្រកទ្វារមួយដ៏ធំបង្ហាញអំពីគោលការណ៍នៃច្បាប់ដ៏ត្រឹមត្រូវរបស់អ៊ីស្លាម ។
- សិក្សាពីការប្រតិបត្តិតាមមាគ៌ារបស់រ៉សូល ។
- យើងអាចដឹងពីប្រវត្តិរបស់ណាហ្ពីហើយអាចជៀសវាងពីការភ័ន្តវង្វេងពីមាគ៌ាដ៏ល្អប្រពៃនេះ ។
- អាចយល់ដឹងអំពីសាសនាអ៊ីស្លាមនិងភាពពិតប្រាកដរបស់សាសនានេះ ដែលមានគំរូពីសំណាក់រ៉សូលទាំងកិច្ចការរស់នៅនិងកិច្ចប្រតិបត្តិចំពោះអល់ឡោះ ។
- អាចយល់ដឹងពីក្រមសីលធម៌សុជីវធម៌ ភាពស្មោះត្រង់របស់លោកតាំងពីកុមារភាព រហូតដល់មរណភាពរបស់លោក ។
- មានជំនឿចំពោះអល់ឡោះនិងចំពោះលោក( ណាហ្ពីមូហាំម៉ាត់) កាន់តែខ្លាំងឡើង ។
- យល់ដឹងពីការរស់នៅនិងការទំនាក់ទំនងក្នុងសង្គមអ៊ីស្លាម ។
- យល់ដឹងពីកិច្ចការប្រតិបត្តិចំពោះអល់ឡោះតាមរយៈទង្វើ និងពាក្យសំដីរបស់លោក ។
- ការយល់ដឹងពីជីវប្រវត្តិរបស់ណាហ្ពីមូហាំម៉ាត់ ជាគ្រឹះមួយនៃគោលជំនឿរបស់សាសនាអ៊ីស្លាម ។



## ឧត្តមភាពនៃជីវប្រវត្តិរបស់ណាហ្ពីមូហាំម៉ាត់ﷺ :

- វាជាប្រវត្តិពិតប្រាកដសំរាប់ប្រវត្តិសាស្ត្ររបស់ណាហ្ពី ដូចជា ឆាកជីវិតរបស់លោកដោយគ្មានអាថ៌កំបាំង ជាដើម ។
- សារដែលលោកបានទទួលពីអល់ឡោះនោះ មិនធ្វើអោយលោកចាកចេញពីលក្ខណៈទូទៅរបស់មនុស្សលោកឡើយ ។
- លោកជាអ្នកចង្អុលបង្ហាញដ៏ប្រពៃ ប្រកបទៅដោយក្រមសីលធម៌ និងសុជីវធម៌ ។
- បង្ហាញពីមាគ៌ាដ៏ត្រឹមត្រូវក្នុងសាសនាអ៊ីស្លាម ។
- អាចជៀសផុតពីភាពមិនត្រឹមត្រូវនិងការប្រឌិតក្នុងកិច្ចការសាសនា ( អ៊ីស្លាម) ។
- រាល់ទង្វើនិងពាក្យសំដីរបស់លោកគឺជាការចង្អុលបង្ហាញពីអល់ឡោះ ។
- មានជំនឿរឹងមាំចំពោះអល់ឡោះ និងរ៉សូលរបស់ទ្រង់ ។
- មូហាំម៉ាត់ជាមនុស្សលោក ។ ដោយពុំមានលក្ខណៈសម្បត្តិជាព្រះជាម្ចាស់ឡើយ ។
- លោកជាណាហ្ពីនិងជារ៉សូលចុងក្រោយបង្អស់ដែលអល់ឡោះតែងតាំងនិងជ្រើសរើសនៅលើផែនដី ។

✲ ✲ ✲

## ភាពខុសប្លែកឧត្តមរបស់បណ្ដាណាហ្គីនិងរ៉ស៊ូល លើមនុស្សលោកទូទៅ

**១-វ៉ាហ៊ុ** [១] ៖ អល់ឡោះបានបញ្ចុះវ៉ាហ៊ុដល់បណ្ដារ៉ស៊ូល តែមិនបានបញ្ចុះដល់មនុស្សលោកទូទៅឡើយ ។អល់ឡោះបានមានបន្ទូលនៅក្នុងគម្ពីរអាល់គួរអានជំពូកអាល់កាស់ហ្វិ(១១០)ថា៖(មូហាំម៉ាត់! ចូរអ្នកមានប្រសាសន៍ថា៖"ពិតណាស់រូបខ្ញុំជាមនុស្សលោក ដូចពួកអ្នកទាំងអស់គ្នាតែគេបញ្ចុះវ៉ាហ៊ីមកអោយខ្ញុំ។ ពិតណាស់ម្ចាស់របស់ពួកអ្នក គឺម្ចាស់តែមួយ ) ។

**២-ភាពគ្មានទោសពៃរ៍** ៖ បណ្ដាណាហ្គី និងរ៉ស៊ូលជ្រះស្អាតអំពីទោសកំហុសនៃបាបកម្មទាំងឡាយ ។

**៣-ការដេក** ៖ បណ្ដាណាហ្គីនិងរ៉ស៊ូលពេលដេកបិទតែភ្នែករបស់ពួកលោកទេ តែចិត្តរបស់ពួកលោកមិនបានដេកឡើយ ។

ហាហ្ទីស្ស [២] រាយការណ៍ដោយអ៊ិបនូហាប់ហ្គានថា ៖ ណាហ្គីមូហាំម៉ាត់ﷺបានមានប្រសាសន៍អំពីរូបលោកថា៖ " ពិតណាស់នេត្រាទាំងពីររបស់ខ្ញុំបានដេកតែចិត្តរបស់ខ្ញុំមិនដេកឡើយ " ។

**៤-ការបញ្ចុះសព** ៖ បណ្ដាណាហ្គី និងរ៉ស៊ូលត្រូវបានគេបញ្ចុះសពរបស់លោកនៅទីកន្លែងដែលលោកទទួលមរណភាព។ នៅក្នុងហាហ្ទីស្សដែលរាយការណ៍

*១-វ៉ាហ៊ុ ៖ បញ្ញត្តិច្បាប់របស់អល់ឡោះដែលផ្ដល់អោយណាហ្គីនិងរ៉ស៊ូលដើម្បីផ្សព្វផ្សាយដល់មនុស្សលោក ។*

*២ -ហាហ្ទីស្ស ៖ រាល់ពាក្យសំដី កាយវិការ ទង្វើ និងការទទួលស្គាល់របស់ណាហ្គីមូហាំម៉ាត់ ។*



ដោយអ៊ីមុាំ [១] អះម៉ាត់ថា៖ សពណាហ្គីមិនត្រូវបានគេបញ្ចុះក្រៅពីទីកន្លែងដែលលោកទទួលមរណៈភាពឡើយ ។

**៥- ដីមិនស៊ីរាងកាយរបស់ណាហ្គីឡើយ**(សាកសពដែលនៅក្នុងដី) ។ នៅក្នុងហាហ្ទីស្សរាយការណ៍ដោយអាហ្គូដាវូដថា៖ពិតណាស់អល់ឡោះបានហាមឃាត់ចំពោះដីក្នុងការស៊ីរាងកាយរបស់បណ្ដាណាហ្គី ។

## បណ្ដាភស្តុតាងមួយចំនួនបង្ហាញពីភាពជាណាហ្គីនិងរ៉ស៊ូលចុងក្រោយ

**១- ភស្តុតាងដ៏ចំបង** ៖ ភស្តុតាងដ៏ប្រពៃដែលអល់ឡោះបានផ្ដល់មកអោយណាហ្គីរបស់យើងដែលជាភស្តុតាងដ៏អស្ចារ្យជាងបណ្ដារ៉ស៊ូលនោះគឺគម្ពីរអាល់គួរអាន ។

**២- អាល់អ៊ីសរ៉ក និងមៀករ៉ាច ៖** ការនាំរ៉ស៊ូលមូហាំម៉ាត់ពីម៉ាក្កះទៅហ្គៃទុលមឹកទិស និងនាំទៅជួបនឹងអល់ឡោះនៅលើមេឃ ។

៣- **ការបំបែកដួងច័ន្ទ៖** ព្រឹត្តិការណ៍ដ៏អស្ចារ្យនេះមានមនុស្សនៅពិភពអារ៉ាប់ និងនៅខាងក្រៅពិភពអារ៉ាប់បានមើលឃើញវា ។

៤- លោកធ្វើអោយអាហារមានច្រើន ( ខណៈពេលអាហារមានតិចនិងសមាជិកមានច្រើន ) ។

៥- លោកធ្វើអោយមានទឹកច្រើនសំរាប់ផឹក និងប្រើប្រាស់ដោយលោកបានបញ្ចេញទឹកតាមម្រាមដៃរបស់លោក ។

៦- អល់ឡោះទទួលយកការបួងសួងរបស់លោក ហើយមនុស្សលោកទាំង

*១ -អ៊ីមុាំ ៖ មេដឹកនាំសាសនាអ៊ីស្លាម ។*

ឡាយទទួលយកការអំពាវនាវរបស់លោក ។

៧ - លោកចេះព្យាបាលជំងឺផ្សេងៗ ។

៨ - លោកផ្តល់ដំណឹងអាថិកំបាំងដូចជា ប្រាប់ដំណឹងអំពីអល់ឡោះបង្ហាញពីបណ្តានាមរបស់ទ្រង់ និងលក្ខណៈរបស់ទ្រង់ ។ ការប្រាប់ដំណឹងអំពីពួកម៉ាឡើអ៊ីកាហ៏[1] អំពីឋានសួគ៌ និងភ្លើងនរក និងអ្វីៗផ្សេងទៀត ។

៩ - មានសញ្ញាត្រាបញ្ជាក់ពីភាពជាណាហ្គី ។ នៅក្នុងសៀវភៅសុក្រិត្យរបស់អ៊ីម៉ាំមូស្លីមអំពីជើហ្បៀរបាននិយាយថាៈខ្ញុំបានឃើញត្រានៅលើខ្នងរបស់រ៉ស៊ូលមានរាងដូចជាពងសត្វព្រាប ។

✡✡✡

*១-ម៉ាឡើអ៊ីកាហ៏ :ពួកទេវៈដែលបំរើការអោយអល់ឡោះជាម្ចាស់ដោយមានភាពស្មោះត្រង់ ។ ពួកគេត្រូវបានអល់ឡោះបង្កើតពីពន្លឺ ។*



# ជំពូកទី១

## ត្រកូលឧត្តុងឧត្តម

អ្នកដែលមានត្រកូលថ្កុំថ្កើងដែលអល់ឡោះបង្កើត ហើយប្រសើរជាងគេក្នុងចំណោមរ៉ស៊ូលរបស់អល់ឡោះជាណាហ្គីចុងក្រោយក្នុងចំណោមណាហ្គីទាំងអស់នោះគឺ**មូហាំម៉ាត់**កូនលោកអាប់ឌុលឡោះ អាប់ឌុលឡោះកូនលោកអាប់ឌុលមូតល់លិប អាប់ឌុលមូតល់លិបកូនលោកហ៊ើស្ហ៊ុម ហ៊ើស្ហ៊ុមកូនលោកអាប់ឌុលម៉ាណាហ្វ អាប់ឌុលម៉ាណាហ្វកូនលោកគូសៃយ៏ គូសៃយ៏កូនលោកគីឡាប គីឡាបកូនលោកមូរ៉ោះ មូរ៉ោះកូនលោក កាអាប់ កាអាប់កូនលោកលូអៃ លូអៃកូនលោកហ្គលិប ហ្គលិបកូន លោកហ្វាហ៊ើរ ហ្វាហ៊ើរកូនលោកម៉ាលិក ម៉ាលិកកូនលោកណាឌ្សើរ ណាឌ្សើរកូនលោកគីណាណះ គីណាណះកូនលោកខូហៃ្សម៉ាស់ ខូហៃ្សម៉ាសកូនលោកមុតរីកះ មុតរីកះកូនលោកអិលយ៉ើស អិលយ៉ើសកូនលោកមូឌើរ មូឌើរកូនលោកណាសហ្សើរ ណាសហ្សើរកូនលោកម៉ាអាត ម៉ាអាតកូនលោកអាត់ណាន ។

**អាត់ណាន** គឺជាពូជតពីណាហ្គីអ៊ីស្មាអ៊ែលជាកូនអ៊ីប៉្រហ៊ីមដោយមានមតិសត្យានុម័ត តែគេមិនបានដឹងចំនួនពិតនិងឈ្មោះអ្នកផ្សេងៗចន្លោះអាត់ណាន និងអ៊ីស្មាអ៊ែលឡើយ ។

ចំនែកឯម្តាយរបស់មូហាំម៉ាត់វិញគឺឈ្មោះ**អាមីណះកូនស្រីលោកវ៉ាហាប់**វ៉ាហាប់កូនលោកអាប់ឌុលម៉ាណាហ្វ អាប់ឌុលម៉ាណាហ្វកូនលោកហ្ស៊ុះរ៉ោះ ហ្ស៊ុះរ៉ោះកូនលោកគីឡាប ។ លោកគីឡាបជាជីតាទី៥របស់ណាហ្គីមូហាំម៉ាត់ ﷺ ពីខ្សែស្រឡាយខាងឪពុករបស់លោក ។ ដូចនេះបង្ហាញអោយ

ឃើញថាមាតាបិតារបស់មូហាំម៉ាត់ពីត្រកូលតែមួយត្រង់លោកគីឡាប ។

**កុលសម្ព័ន្ធរបស់មូហាំម៉ាត់ﷺ**:កុលសម្ព័ន្ធរបស់លោកមូហាំម៉ាត់គឺគូរ៉ស្សៃ ដែលល្បីល្បាញពីភាពថ្កុំថ្កើង និងឋានៈឧត្តុង្គឧត្តមក្នុងពូជពង្សអារ៉ាប់ទាំងអស់ ។

ពួកប្រុសដែលចេញពីកុលសម្ព័ន្ធនេះសុទ្ធតែជាអ្នកដឹកនាំ និងជាអ្នកមានមុខមាត់ក្នុងជំនាន់របស់ខ្លួន ពិសេសនោះគឺលោកគូសៃយ៏នេះតែម្តង ។

**ក្រុមគ្រួសារមូហាំម៉ាត់ﷺ**:ក្រុមគ្រួសារមូហាំម៉ាត់ត្រូវបានគេស្គាល់ថា ជាគ្រួសារអាល់ហ៊ើស្ហ៊ិមជាប់ត្រកូលជីតារបស់លោកគឺលោកហ៊ើស្ហ៊ិម ហើយលោកហ៊ើស្ហ៊ិមបានទទួលមតិកពីគុណប្រយោជន៏របស់លោកគូសៃយ៏ ។

**ព្រឹត្តិការណ៏ឆ្នាំដំរី :**

មូលហេតុនៃព្រឹត្តិការណ៏នេះមានដូចតទៅ : លោកអាប់រ៉ហះកូនអាស់សប់ហ្គើសគ្រប់គ្រងនៅទឹកដីប្រទេសយ៉េម៉ែន ដែលជាគូកនរបស់ស្តេចហាហ្គើសះឈ្មោះណាជើស្ហ៊ី ដោយមើលឃើញពីការទៅធ្វើហាជ្ជី[១] នៅហ្គៃទុលឡោះ[២] ដែលអល់ឡោះបានលើកតំកើងដល់មនុស្សម្នា នារដូវបុណ្យហាជ្ជ អាប់រ៉ហះក៏បានរៀបចំសាងសង់ព្រះវិហារគ្រីស្ទានមួយ នៅទីក្រុងសន់អា (ទីក្រុងនៅប្រទេសយ៉េម៉ែន)រួចលោកបានសរសេរលិខិតមួយច្បាប់ផ្ញើជូនស្តេចណាជើស្ហ៊ី ដោយទូលថ្វាយថា : " ទូលព្រះបង្គំបានសាងសង់ព្រះវិហារ

*១-ហាជ្ជី : ការធ្វើបុណ្យសាសនាអ៊ីស្លាមប្រចាំឆ្នាំដោយធ្វើធម្មយាត្រាទៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត រៀងរាល់ឆ្នាំ នៅខែទី១២ មូហាំម៉ាត់សករាជ ។*

*២ -ហ្គៃទុលឡោះ : កាក់ហ្ពះ ជាកន្លែងដែលមូស្លីមគ្រប់រូបតំរង់ឆ្ពោះទៅ ក្នុងពេលធ្វើកិច្ចសក្ការៈចំពោះអល់ឡោះ ។*



គ្រីស្ទានមួយយ៉ាងល្អឥតខ្ចោះ ដែលគ្មានគូរប្រដូចសំរាប់ទ្រង់ដើម្បីអោយអ្នកធ្វើបុណ្យហាជ្ជអារ៉ាប់ទាំងអស់វិលមកទីនេះវិញ" ។

មានបុរសម្នាក់មកពីអំបូរគីណាណាស់បានលឺពតិមាននេះក៏លបចូលទៅក្នុងព្រះវិហារនេះនៅពេលយប់ ហើយបានធ្វើអោយគឺបឡាត់របស់ព្រះវិហារនោះប្រលាក់ ។ គេបានប្រាប់រឿងនេះដល់លោកអាប់រ៉ហះ ។ ពេលនោះអាប់រ៉ហះបានសួរថាៈតើអ្នកណាហ៊ានធ្វើដូចនេះ? គេបានប្រាប់គាត់ថាមានបុរសម្នាក់មកពីបៃទុលឡោះ ។ពេលនោះអាប់រ៉ហះបានស្បថថានឹងធ្វើដំណើរទៅកាន់កាក់ហ្ពះ[១] ដើម្បីកំទេចវាចោល ។ អាប់រ៉ហះក៏បានសរសេរលិខិតមួយច្បាប់ទូលស្តេចណាជើស្ហ៊ីអំពីរឿងនេះនិងស្នើរសុំដំរីព្រះអង្គដោយសារព្រះអង្គមានដំរីឈ្មោះម៉ាស់មូដដែលមានមាឌធំអស្ចារ្យគ្មានគូរប្រៀប ។ ស្តេចណាជើស្ហ៊ីបានបញ្ជូនដំរីតាមសំណើរអាប់រ៉ហះមែន ។ អាប់រ៉ហះក៏ចាប់ផ្តើមចេញមកកំទេចកាក់ហ្ពះ ។ ពេលនោះពពួកអារ៉ាប់បានដឹងពីដំណឹងនេះក៏ចាប់ផ្តើមចេញតទល់ដើម្បីរារាំងអាប់រ៉ហះមិនអោយទៅកំទេចកាក់ហ្ពះ ។ មានស្តេចមួយអង្គមានព្រះនាមថា ហ្សូណាហ្វើរក្នុងចំណោមស្តេចជាច្រើនអង្គរបស់ប្រទេសយ៉េម៉ែនបានចេញមកតតាំងនឹងអាប់រ៉ហះតែត្រូវចាញ់ដៃអាប់រ៉ហះហើយបានក្លាយជាឈ្លើយសឹករួចបានមានបន្ទូលទៅកាន់អាប់រ៉ហះថាៈ សូមព្រះអង្គទុកជីវិតទូលបង្គំចុះព្រោះវាមានប្រយោជន៏ដល់ព្រះអង្គ ។ អាប់រ៉ហះក៏ទុកជីវិតអោយពួកគេ ។ អាប់រ៉ហះបានបន្តដំណើររហូតដល់

*១- កាក់ហ្ពះ: ជាកន្លែងដែលមូស្លីមគ្រប់រូបតំរង់ឆ្ពោះទៅ ក្នុងពេលធ្វើកិច្ចសក្ការៈចំពោះអល់ឡោះ ។*

តំបន់ខសអាំ ក៏មានបុរសម្នាក់ឈ្មោះ នូហៃហ្វហ៊្ពិនហាហ៊្ពីប ខសអាំបានកែនប្រមូលកុលសម្ព័ន្ធពួកអារ៉ាប់ចេញតតាំងប្រឆាំងអាប់រ៉ហេះ តែត្រូវចាញ់ដៃអាប់រ៉ហេះដដែល ។អាប់រ៉ហេះបានចាប់នូហៃហ្វធ្វើជាឈ្លើយសឹក ។ នូហៃហ្វបានសុំអង្វរអាប់រ៉ហេះថា"សូមព្រះអង្គទុកជីវិតអោយទូលព្រះបង្គំចុះទូលបង្គំជាអ្នកបង្ហាញផ្លូវដល់ព្រះអង្គ" ។អាប់រ៉ហេះក៏បានទុកជីវិតឱ្យឈ្លើយសឹកនោះ ។ នៅពេលអាប់រ៉ហេះនិងបរិវារឆ្លងកាត់តំបន់តអ៊ីហ្វមានបុរសម្នាក់ឈ្មោះម៉ាសអ៊ូដកូនមួកតាប់បានចេញមកជួបរួចនិយាយថាៈ " ព្រះអង្គម្ចាស់! ពួកខ្ញុំជាបំរើរបស់ទ្រង់ ពួកយើងខ្ញុំអាចចាត់តាំងអ្នកបង្ហាញផ្លូវដល់ព្រះអង្គបាន" ។ ពួកគេបានចាត់អោយអាហ្ពូរីហ្គលជាបំរើសំរាប់អាប់រ៉ហេះនិងបរិវារ ។ លុះពេលចេញដំណើរដល់តំបន់មួយឈ្មោះមូហ្គំម៉ាស់អាហ្ពូរីហ្គលបានទទួលមរណៈភាព ( អាហ្ពូរីហ្គលនេះហើយគឺជាជនដែលត្រូវគេគប់ផ្នូរគាត់) ។ ក្រោយមកអាប់រ៉ហេះបានចាត់តាំងអាសវ៉ាត់កូនម៉ាហ្វស៊ូដជាអ្នកដឹកនាំទ័ពសេះនិងបានបញ្ជាអោយប្រមូលទ្រព្យសម្បត្តិរបស់អ្នកភូមិ ។ អាសវ៉ាត់ក៏បានរឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកភូមិទាំងបង្ខិតបង្ខំបំពានច្បាប់ ។ ពេលនោះគេប្រមូលបានអូដ្ឋរបស់លោកអាប់ឌុលមូតល់លិបចំនួន ២០០ក្បាលផងដែរ ។

ក្រោយមកគេបានប្រើបុរសម្នាក់មកពីតំបន់ហាមៀរអោយទៅប្រាប់ពួកអ្នកស្រុកម៉ាក្កះអោយប្រាប់មេដឹកនាំរបស់ពួកគេថាៈ"ពួកយើងមកនេះមិនមែនដើម្បីធ្វើសង្គ្រាមអ្វីឡើយ ។តែយើងមកនេះគឺដើម្បីកំទេចកាក់ហ្ពះប៉ុណ្ណោះ" ។បុរសនោះក៏បានប្រាប់តាមបញ្ជានោះ ។អាប់ឌុលមូតល់លិបបានតបវិញថាៈ"ពួកយើងគ្មានអ្វីក្រៅពីដៃពីរទេ ។ ពួកយើងនឹងមិនខ្វល់ពីអ្វីដែល



អាប់រ៉ហេះប្រាថ្នានោះទេ ។នេះជាហ្ពៃទុលឡោះនិងជាទីស្រលាញ់របស់ទ្រង់ បើទ្រង់រារាំងអាប់រ៉ហេះក៏វាជាកាក់ហ្ពះរបស់ទ្រង់ តែបើទ្រង់មិនរារាំងទេក៏វាជាអំណាចរបស់ទ្រង់ ។ខ្ញុំសូមស្បថនឹងអល់ឡោះថាពួកយើងគ្មានអំណាចអ្វីឡើយ" ។បុរសរូបនោះបាននិយាយទៅកាន់អាប់ឌុលមូតល់លិបថាៈ" ចូរលោកទៅជាមួយខ្ញុំដើម្បីជួបព្រះអង្គ( អាប់រ៉ហេះ) ដែលជាមិត្តភក្តិរបស់ខ្លួនហើយក៏បាននិយាយថាៈ " ឱ! ហ្សូណាហ្វើរ តើសំលាញ់មានមធ្យោបាយអ្វីអាចជួយដល់ពួកយើងបានដែរឬទេ?" ។ហ្សូណាហ្វើរបានតបវិញថាៈ" គ្មានទេ ព្រោះខ្ញុំជាឈ្លើយសឹក ។ មិនដឹងថាគេសំលាប់ពេលល្ងាចឬនៅថ្ងៃស្អែកនោះឡើយ? តែខ្ញុំអាចជួយអោយអ្នកបានទៅជួបអ៊ូណៃស៏ ដែលជាហ្មរដីរព្រោះអ៊ូណៃស៏ជាមិត្តរបស់ខ្ញុំ ហើយខ្ញុំនឹងសំណូមពរអ៊ូណៃស៏អោយបញ្ជាក់រឿងហេតុរបស់អ្នកដល់ព្រះអង្គ ។ ក្រោយពីបានជួបជាមួយអ៊ូណៃស៏រួចរាល់ហើយអ៊ូណៃស៏ក៏បាននាំទៅជួបអាប់រ៉ហេះ ។រួចក៏ទូលថ្វាយថាៈ" នេះជាមេគូរ៉ស្សមកសុំអនុញ្ញាតជួបព្រះអង្គ ។គាត់មកនេះគ្មានអ្វីមកថ្វាយព្រះអង្គទេនិងមិនប្រឆាំងព្រះរាជកិច្ចរបស់ព្រះអង្គដែរ ។ ខ្ញុំសំណូមពរដល់ព្រះអង្គអនុញ្ញាតអោយគាត់បានជួបព្រះអង្គផង" ។ អាប់ឌុលមូតល់លិបជាបុរសសង្ហាមាឌធំស្អាត ។ ពេលអាប់រ៉ហេះបានឃើញក៏បានយកចិត្តទុកដាក់ចំពោះគាត់ហើយក៏សុខចិត្តចុះពីលើគ្រែស្នែងមកអង្គុយជាមួយអាប់ឌុលមូតល់លិបលើកន្ទេលខាងក្រោមវិញ ។ អាប់ឌុលមូតល់លិបសុំអាប់រ៉ហេះអោយផ្តល់សត្វអូដ្ឋពីររយក្បាលមកអោយលោកវិញ ។ ពេលនោះអាប់រ៉ហេះក៏បាននិយាយទៅកាន់អ្នកបកប្រែរបស់ខ្លួនថាៈ"ចូរនិយាយប្រាប់គាត់( អាប់ឌុលមូតល់លិប) ថាៈខ្ញុំមានចំណាប់អារម្មណ៏ចំពោះអ្នកពេលខ្ញុំបានឃើញអ្នក!ខ្ញុំហួសចិត្តនឹង

អ្នក"។ អាប់ឌុលមូតល់លិបបានតបវិញថា : " ហេតុអ្វី? " អាប់រ៉ាហះ បានឆ្លើយតបថា:" ខ្ញុំមករកកាក់ហ្ពះដែលជាសាសនារបស់អ្នកជាសាសនារបស់ជីដូនជីតារបស់អ្នកនិងជាកន្លែងថ្ពុំថ្កើងរបស់ពួកអ្នក ដើម្បីខ្ញុំនឹងកំទេចវាចោល ។ តែអ្នកមិនព្រមនិយាយរឿងនេះទេ បែរជាអ្នកមកនិយាយរឿងសត្វអូដ្ឋពីររយក្បាលទៅវិញ"។ អាប់ឌុលមូតល់លិបបានតបវិញថា: "រូបខ្ញុំជាម្ចាស់របស់សត្វអូដ្ឋ ចំណែកឯកាក់ហ្ពះមានម្ចាស់របស់វា ដែលរារាំងព្រះអង្គពីការកំទេចវា"។ អាប់រ៉ាហះបានឆ្លើយតបវិញថា : "អល់ឡោះមិនអាចរារាំងខ្ញុំបានឡើយ"។ អាប់ឌុលមូតល់លិបតបវិញថា : " វាជារឿងរបស់ព្រះអង្គ"។

ក្រោយមកអាប់រ៉ាហះបានបញ្ជាអោយគេផ្តល់សត្វអូដ្ឋនោះទៅអាប់ឌុលមូតល់លិបវិញ ។ ក្រោយពីអាប់ឌុលមូតល់លិបត្រឡប់មកវិញក៏បានប្រាប់រឿងនេះដល់ពួកគូរ៉ៃស្សទាំងអស់រួចក៏បញ្ជាអោយបំបែកគ្នាទៅតាមជ្រលងភ្នំនិងតាមកំពូលភ្នំដោយការខ្លាចពីភាពគ្មានប្រណីរបស់កងទ័ពអាប់រ៉ាហះ។ ពួកគូរ៉ៃស្សទាំងអស់ក៏បានធ្វើតាមបញ្ជារបស់អាប់ឌុលមូតល់លិបមែន។ ចំណែកអាប់ឌុលមូតល់លិបបានដើរទៅកាន់កាក់ហ្ពះដោយចាប់ទ្វារកាក់ហ្ពះរួចបួងសួងសុំថា:" ឱ!ម្ចាស់របស់ខ្ញុំ ខ្ញុំគ្មានសង្ឃឹមអ្នកណាក្រៅពីទ្រង់ឡើយ។ ឱ! ម្ចាស់របស់ខ្ញុំ សូមទ្រង់រារាំងពួកគេដោយការការពាររបស់ទ្រង់ផងចុះ។ ពិតណាស់សត្រូវរបស់កាក់ហ្ពះ គឺជនណាហើយដែលប្រឆាំងចំពោះទ្រង់។ សូមទ្រង់រារាំងពួកគេកុំអោយកំទេចកាក់ហ្ពះរបស់ទ្រង់ផង" ។ បន្ទាប់មកលោកអាប់ឌុលមូតល់លិបនិងក្រុមរបស់លោកបាននាំគ្នាឡើងលើភ្នំនិងនៅតាមជ្រលងភ្នំ ។អាប់រ៉ាហះ បានត្រៀមនិងបញ្ជាទ័ពអោយសំរុកចូលដោយ



បញ្ជានូហ្វៃទៅកាន់ហ្វូងដំរីរួចប្រកាស់ថា:"ចូរសំរុកចូលម៉ាស់មូដ!ឯងឥឡូវនេះនៅទឹកដីពិសិដ្ឋរបស់អល់ឡោះ។ ដំរីបែរជាលុតជង្គង់ចុះទោះបីប្រើយ៉ាងណាក៏វានៅតែមិនព្រមធ្វើតាម។ តែបើបំបែរវាទៅទិសប្រទេសយ៉េម៉ែន ឬប្រទេសស្ហាម[១] វាក្រោកឈរឡើងរត់ទៅតែម្តង។ ពេល នូហ្វៃចាប់ផ្តើមបញ្ជាវាកាន់តែខ្លាំងឡើង វាក៏រត់ឡើងលើភ្នំ។ ពេលនោះអល់ឡោះបានបញ្ជូនសត្វមួយប្រភេទមកពីទិសសមុទ្រ ។រាល់សត្វនីមួយៗ មានពាំមកនូវកូនថ្មបីដុំ( ថ្មនេះយកមកពីភ្លើងនរក) ដោយពីរដុំនៅនឹងជើងទាំងពីរនិងមួយដុំនៅនឹងជំពុះវា ។គ្រប់គ្រាប់ថ្មទាំងនេះពេលទំលាក់ទៅលើក្រុមរបស់អាប់រ៉ាហះប៉ះត្រូវខ្ទេច តែមិនត្រូវចំទៅលើគ្រប់ៗគ្នានោះទេ ។អ្នកដែលនៅមានជីវិតបានភៀសខ្លួនចេញដោយសុំអោយ នូហ្វៃ ជួយបង្ហាញផ្លូវពួកគេទៅកាន់ប្រទេសយ៉េម៉ែន។ ម្នាក់ៗរត់យកតែអាយុហើយទទួលរងនូវការវិនាសជាបន្តបន្ទាប់។ ដោយឡែកអាប់រ៉ាហះបានរត់ចេញទៅទាំងមានជំងឺជាប់នឹងខ្លួនថែមទៀត។ ម្រាមដៃជ្រុះធ្លាក់រហូតបានទៅដល់ទីក្រុងសន់អាមានសភាពដូចជាកូនសត្វ ។ក្រោយមកត្រូវស្លាប់ដោយប្រេះទ្រូងតែម្តង។ ដូចអល់ឡោះមានបន្ទូលទាក់ទងនឹងប្រវត្តិនេះនៅក្នុងគម្ពីរអាល់គូរអានជំពូកហ្វីល( សត្វដំរី) មានន័យថា:"អ្នក( មូហាំម៉ាត់) មិនបានឃើញទេឬតើម្ចាស់របស់អ្នកបានធ្វើដូចម្តេចខ្លះទៅលើពួកកងទ័ពដំរី?តើអល់ឡោះមិនបានធ្វើអោយកលល្បិចរបស់ពួកនេះទទួលនូវការបរាជ័យទេឬ ? អល់ឡោះបានបញ្ជូនសត្វស្លាបមកកំទេចពួកនេះ។ សត្វស្លាបទាំងនេះបានទំលាក់ដុំក្រួស

---

*១ - ប្រទេសស្ហាម: ប្រទេសស៊ីរីបច្ចុប្បន្ន ។*

ដែលពាំមកពីនរកអវចីយ៍ ។ អល់ឡោះបានធ្វើអោយពួកនោះ ដូចជាស្លឹកឈើដែលត្រូវដង្កូវស៊ីអញ្ចឹង" ។

## កំណើតណាហ្គីមូហាំម៉ាត់ ﷺ:

"រ៉សូលុលឡោះﷺបានកើតក្នុងត្រកូលហ៊ាស៊ីមនៅទីក្រុងម៉ាក្កះ[១] នាព្រឹកថ្ងៃច័ន្ទទី៩( មតិខ្លះថាថ្ងៃទី១២) ខែរ៉ប៊ីអ៊ុលអៅវ៉ាល់ត្រូវនឹងឆ្នាំដំរី ។ ចំពោះថ្ងៃទី៩គឺវាត្រឹមត្រូវជាង ។តែថ្ងៃទី១២វាមានភាពល្បីសុះសាយជាង ។ពេលវេលានោះវាត្រូវនឹងថ្ងៃទី២២ខែមេសាឆ្នាំ៥៧១គ.ស ។ មុនកំណើតណាហ្គី**មូហាំម៉ាត់**ម្តាយរបស់លោកបានយល់សប្តិឃើញថា មានរស្មីចេញពីអ្នកស្រីរួចវាបញ្ចេញពន្លឺរហូតបានឃើញរាជវាំងនៅទីក្រុងប្រទេសស្ហាម ។អ្នកស្រីបានបញ្ជូនទារក**មូហាំម៉ាត់**ទៅអោយជីតារបស់គេដើម្បីអោយលោកមានការសប្បាយរីករាយពីកំណើតចៅប្រុសរបស់លោក ។លោក**អាប់ឌុលមូតល់លិប**រីករាយយ៉ាងខ្លាំង ។ លោកបីចៅចូលក្នុងកាក់ហ្ពះសំដែងការអរគុណចំពោះអល់ឡោះនិងបានបួងសួងសុំពីទ្រង់ ។ រួចលោកបានដាក់ឈ្មោះចៅថា **មូហាំម៉ាត់** ដោយក្តីប្រាថ្នាអោយគេកោតសរសើរ ។ ក្រោយមកលោកបានខតាន់ (សំអាតប្រដាប់ភេទ) **មូហាំម៉ាត់**នៅថ្ងៃទី៧ និងបានផ្តល់ចំនីអាហារដល់មនុស្សម្នាដូចដែលទំលាប់អារ៉ាប់ធ្វើ ។ណាហ្គីបានមានប្រសាសន៏ថា:"ខ្ញុំជាកូនរបស់អ្នកដែលត្រូវគេសំឡេះទាំងពីរ" ។ ពាក្យនេះមានប្រវត្តិដំណើររឿងដូចតទៅ :

*១ - ឈ្មោះទីក្រុងមួយនៅប្រទេសអារាប៊ីសាអូឌីតដែលជាដីពិសិដ្ឋរបស់អល់ឡោះ ។*



ពេលលោកអាប់ឌុលមូតល់លិបចាប់ផ្តើមជីកកកាយរកអណ្តូងហ្សាំហ្សាំ[១] បន្ទាប់ពីបានយល់សប្តិឃើញថា គេប្រើអោយលោកជីកស្តាររកអណ្តូងនេះឡើងវិញ ។ ពេលលោកជីកនេះលោកបានឃើញរបស់របរជាច្រើននៅក្នុងអណ្តូងដោយសារការបោះចូលផ្សេងសំណាងពីអ្នកមុនៗ ។ ពេលនោះក៏មានអំបូរផ្សេងៗទៀតក្រៅពីអំបូរគូរ៉ស្សចង់ចូលរួមក្នុងស្តារអណ្តូងនេះដែរ តែអាប់ឌុលមូតល់លិបបានរារាំង ហើយវាកើតជាសង្គ្រាមរវាងគ្នានឹងគ្នា ។ អាប់ឌុលមូតល់លិបបានសច្ចាចំពោះអល់ឡោះថា: "បើអល់ឡោះប្រទានកូនអោយគាត់បានចំនួនដប់នាក់ ដើម្បីតតាំងជាមួយអំបូរផ្សេងៗដែលមកយាយីពួកគាត់ គាត់នឹងសំឡេះកូនម្នាក់ ។លុះពេលកូនលោកបានចំនួនគ្រប់ដប់នាក់ដូចសេចក្តីប្រាថ្នានោះ**អាប់ឌុលមូតល់លិប**ក៏នាំអាប់ឌុលឡោះដែលត្រូវជាឪពុករបស់ណាហ្គីមូហាំម៉ាត់ទៅកាន់កាក់ហ្ពះដើម្បីសំឡេះនៅទីនោះតែម្តង ។ពេលនោះអំបូរអារ៉ាប់ផ្សេងទៀតមកធ្វើការហាមឃាត់ដោយមិនអនុញ្ញាតអោយធ្វើដូចនោះឡើយ ។ ក្រោយមកក៏កើតឡើងនៅការបោះឆ្នោតរវាងអាប់ឌុលឡោះនិងសត្វអូដ្ឋដប់ក្បាល ។ រាល់ពេលចាប់យកមកគឺចំតែទៅលើអាប់ឌុលឡោះ ។ ការចាប់ឆ្នោតកើតឡើងចំនួនដប់ដង ហើយនៅលើកទីដប់ក៏ចំទៅលើសត្វអូដ្ឋ ។ដូចនេះទើបអាប់ឌុលមូតល់លិបសំឡេះសត្វអូដ្ឋចំនួន១០០ក្បាល ជំនួសអាប់ឌុលឡោះវិញ ។ ត្រង់នេះហើយទើបណាហ្គីមានប្រសាសន៏ដូចបញ្ជាក់ខាងដើមនិងចំនុចមួយទៀតដោយសារថាណាហ្គីជាប់ខ្សែលោហិតនឹងណាហ្គីអ៊ីស្មាអ៊ែលដែលត្រូវអល់ឡោះបញ្ជាសាក

*១-អណ្តូងហ្សាំហ្សាំ:ជាឈ្មោះអណ្តូងទឹកមួយនៅជិតកាក់ហ្ពះ ។*

ល្បងណាហ្គីអ៊ីប៉័រហ៊ីមដើម្បីសំឡេះណាហ្គីអ៊ីស្មាអ៊ែល តែក្រោយមកត្រូវអល់ឡោះផ្តល់អោយយកសត្វពពែមកសំឡេះជំនួសវិញ ។

☪ -ការបំបៅដោះ

អ្នកដែលបំបៅដោះមូហាំម៉ាត់ﷺមុនគេបន្ទាប់ពីម្តាយរបស់លោកគឺអ្នកស្រីស៊ូវៃហ្ពះ ។ នាងធ្លាប់បានបំបៅហាំហ្ស៊ះកូនអាប់ឌុលមូតលិបមុនមូហាំម៉ាត់ និងបំបៅអាហ្ពូសើឡើម៉ាស់កូនអាប់ឌុលអាសាត់ បន្ទាប់ពីមូហាំម៉ាត់ទៀត ។ ដូចនេះបង្ហាញអោយឃើញថាពួកគេជាពោះមួយនឹងគ្នាក្នុងការបំបៅដោះ ។

☪ - នៅក្នុងត្រកូលហ្ពើនីសាអាត់

តាមទំលាប់អារ៉ាប់តែងតែរកអ្នកបំបៅកូនចៅរបស់ខ្លួននៅតាមជនបទដើម្បីជៀសឆ្ងាយពីជំងឺដំកាត់ផ្សេងៗអោយរាង្គកាយរឹងមាំនិងដើម្បីអោយភាសាអារ៉ាប់របស់គេច្បាស់លាស់ល្អ ។ តាមការរៀបចំជាស្រេចរបស់អល់ឡោះជាម្ចាស់ក៏មានស្ត្រីជាច្រើនមកពីត្រកូលសាអាត់កូនហ្ពើកើរ ស្វែងរកក្មេងដើម្បីបំបៅដោះ ។ គេបានបង្ហាញក្មេងមូហាំម៉ាត់ដល់ពួកស្ត្រីទាំងនោះតែម្នាក់ៗបានប្រកែកមិនព្រមទទួលយកទៅបំបៅឡើយ ដោយសារក្មេង**មូហាំម៉ាត់**គ្មានឪពុកដូចគេ ។តែអ្នកស្រីហាលីម៉ាស់ដែលជាអ្នកបំបៅដែរនោះព្រមទទួលយកក្មេងមូហាំម៉ាត់ទៅបំបៅដើម្បីបានចំនែកដូចគេដូចឯងដែរ ។

☪ -ការស្នាក់នៅរបស់ណាហ្គី ﷺ នៅជាមួយអម្បូរសាអាត់

ពិតណាស់ហាលីម៉ះតែងតែនាំណាហ្គីមូហាំម៉ាត់ទៅលេងជាមួយម្តាយនិងក្រុមគ្រួសាររបស់លោករៀងរាល់៦ខែម្តង ។ ក្រោយមកក៏នាំត្រឡប់



មកតំបន់ជនបទនៃអម្បូរសាអាត់វិញ ។ នៅពេលគំរប់ពេលនៃការបំបៅហើយនោះអ្នកស្រីក៏នាំលោកមកកាន់មាតារបស់លោក ហើយក៏សំនូមពរពីមាតារបស់លោក សុំអនុញ្ញាតអោយលោកបានស្នាក់នៅជាមួយលោកស្រីបន្តទៀតរហូតដល់លោករឹងមាំ ។មាតារបស់លោកក៏យល់ព្រមតាមសំណើនេះ ។ អ្នកស្រីហាលីម៉ះក៏បានវិលត្រឡប់មកផ្ទះវិញយ៉ាងរីករាយ ។ ណាហ្គីបានស្នាក់នៅទីនោះប្រហែលរយៈពេលពីរឆ្នាំ ។ក្រោយមកមានព្រឹត្តិការណ៍ចំឡែកមួយដែលធ្វើអោយអ្នកស្រីហាលីម៉ះ និងស្វាមីរបស់គាត់មានការភិតភ័យយ៉ាងខ្លាំងរហូតដល់បញ្ជូនលោកទៅកាន់ម្តាយរបស់លោកវិញ ។ ព្រឹត្តិការណ៍នោះគឺការពុះទ្រូងរបស់ណាហ្គី**មូហាំម៉ាត់** ។

☪ -ព្រឹត្តិការណ៍ពុះទ្រូងណាហ្គីមូហាំម៉ាត់ ﷺ

មានសេចក្តីរាយការណ៍អំពីអាណែសកូនម៉ាលិកបាននិយាយថាពិតណាស់ជីប៊្រអ៊ីលបានមកជួបរ៉ស៊ូលុលឡោះខណៈពេលលោកកំពុងរត់លេងជាមួយក្មេងៗ ។គេ( ម៉ាឡើអ៊ីកាហ៍) ក៏ចាប់លោករួចផ្តួលទៅដីហើយក៏ពុះទ្រូងយកបេះដូងចេញព្រមទាំងយកដុំឈាមមួយចេញពីក្នុងនោះទៀតផង ដោយបានពោលថា : " នេះជាចំណែកមួយរបស់ស្វៃតនដែលនៅក្នុងខ្លួនឯង ។ ក្រោយមកជីប៊្រអ៊ីលបានលាងសំអាតបេះដូងនោះក្នុងផើងមាសមួយដោយប្រើទឹកហ្សាំហ្សាំ ។បន្ទាប់មកក៏បានបិទភ្ជាប់វិញ ហើយបញ្ជូនរូបលោកមកកាន់កន្លែងដើម ។ ចំណែកពួកក្មេងៗបានរត់មកប្រាប់ម្តាយ( មេដោះ) របស់មូហាំម៉ាត់ថា ពិតណាស់**មូហាំម៉ាត់**ត្រូវបានគេសំលាប់ទៅហើយ ។ពួកគេក៏

នាំគ្នារត់ទៅរកមូហាំម៉ាត់ ។ពេលទៅដល់ក៏ជួបមូហាំម៉ាត់ តែរូបលោកមានសភាពប្រែពណ៌(ស្លេកស្លាំង)ខុសពីធម្មតា ។

## ណាប៊ីមូហាំម៉ាត់ ﷺ ត្រឡប់ទៅនៅជាមួយមាតា

ក្រោយពីមានព្រឹត្តិការណ៍ដ៏ចំឡែកនេះលោកក៏ត្រូវបានបញ្ជូនវិលត្រឡប់ទៅរស់នៅជាមួយមាតារបស់លោកវិញ ។ ការស្នាក់នៅជាមួយមាតានិងក្រុមគ្រួសាររបស់លោកបានរយៈពេលប្រហែលពីរឆ្នាំ(អាយុ៦ឆ្នាំ) ។ ក្រោយមកលោកក៏បានធ្វើដំណើរជាមួយមាតារបស់លោកទៅកាន់ម៉ាឌីណះ ហើយនៅតាមផ្លូវពួកគាត់ក៏ចូលទៅហ្យីយ៉ារ៉ោះ[១] ផ្នូរស្វាមីរបស់លោកស្រីនិងសាច់សាលោហិតខាងជីតារបស់លោកគឺអំបូរអាត់ឌីកូនអាន់ណាច់ជើរ ។ ពួកគាត់បានស្នាក់នៅទីនោះរយៈពេលមួយខែ ។ ក្រោយមកពួកគាត់ក៏វិលត្រឡប់មកវិញ ។ តែនៅពេលដល់ពាក់កណ្តាលផ្លូវលោកស្រី(មាតារបស់មូហាំម៉ាត់)ចាប់ផ្តើមមានជំងឺ ។ ជំងឺកាន់តែធ្ងន់ធ្ងររហូតលោកស្រីទទួលអានិច្ចកម្មនៅកន្លែងមួយឈ្មោះ"**អាប់វ៉ាក** "ដែលស្ថិតចន្លោះក្រុងម៉ាក្កះនិងម៉ាឌីណះ ។

ក្រោយមកជីតារបស់លោកក៏បាននាំលោកវិលត្រឡប់មកក្រុងម៉ាក្កះវិញដោយរូបលោកទទួលរងនូវការឈឺចាប់យ៉ាងខ្លាំង ។ អាប់ឌុលមូតល់លិបស្រលាញ់ចៅរបស់គាត់ពោរពេញដោយមេត្តាធម៌ ។ ជីតារបស់លោកទទួល

*១-ហ្យីយ៉ារ៉ោះ : ទស្សនា មើល ។*



មរណៈភាពបន្ទាប់ពីការស្នាក់នៅរបស់លោកទីនោះរយៈពេលពីរឆ្នាំ ខណៈពេលនោះលោកមានអាយុ ៨ ឆ្នាំ ២ ខែ ១០ ថ្ងៃ ។

បន្ទាប់មកអាប៊ូតលិបត្រូវជាមារបស់លោកបានយកលោកទៅថែរក្សាប្រកបដោយក្តីអាណិតស្រលាញ់បំផុត ។ គាត់នៅតែបន្តការការពារក្មួយរបស់គាត់រហូតដល់អាយុជាង៤០ឆ្នាំ ។

### ☪ -ជីវិតការងាររបស់ណាប៊ីមូហាំម៉ាត់ ﷺ

ពិតណាស់ណាប៊ីជាកូនកំព្រារស់នៅក្រោមការគាំពាររបស់ជីតានិងមាដោយមិនបានទទួលមត៌កពីបិតារបស់លោកបន្តិចសោះឡើយ ។ នៅពេលលោកមានអាយុអាចបំពេញការងារបានលោកក៏ទៅឃ្វាលពពែជាមួយបងប្អូនរួមទឹកដោះក្នុងអំបូរសាអាត់ ។នៅពេលលោកត្រឡប់ទៅម៉ាក្កះលោកក៏ស៊ីឈ្នួលឃ្វាលសត្វអោយគ្រួសាររបស់ពួកគេដែរ ។

### ☪ -ការធ្វើដំណើររបស់មូហាំម៉ាត់ទៅស្រុកស្វាមនិងការធ្វើជំនួញ

លោកស្រី**ខឌីជះ**កូនស្រីវ៉ាលីត ពិតជាស្រ្តីម្នាក់ដែលមានកិត្តិយសឧត្តុង្គឧត្តមលើសស្ត្រីផ្សេងៗ ទាំងកិត្តិយសនិងទ្រព្យសម្បត្តិ ។ លោកស្រីបានប្រើទ្រព្យសម្បត្តិជាច្រើនអោយមនុស្សម្នាធ្វើជំនួញដោយគិតជាឈ្នួលដល់ពួកគេ ។នៅពេលដែលលោកស្រីបានលឺភាពល្បីល្បាញនៃការវៃឆ្លាតនិងស្មោះត្រង់របស់មូហាំម៉ាត់លោកស្រីក៏បានប្រគល់ទ្រព្យសម្បត្តិឬទំនិញល្អៗនិងមានតំលៃខ្ពស់ដែលពុំធ្លាប់ផ្តល់អោយនរណាម្នាក់កាលពីមុនដល់មូហាំម៉ាត់ដើម្បីធ្វើជំនួញនៅប្រទេសស្វាម ។

ក្រោយមកមូហាំម៉ាត់ក៏យកទំនិញទាំងនោះទៅជាមួយក្មេងប្រុសម្នាក់ឈ្មោះ**មៃសារ៉ស់**ធ្វើដំណើរទៅស្រុកស្ហាម ។ លុះពេលទៅដល់លោកបានលក់ទំនិញទាំងនោះអស់និងបានទទួលប្រាក់ចំណេញយ៉ាងច្រើន ។ ដោយសារទ្រព្យសម្បត្តិល្អធ្វើអោយមានការកើនឡើងជាបន្តបន្ទាប់ ដែលពុំធ្លាប់ជួបប្រទះពីមុនមក ។ មូហាំម៉ាត់បានវិលត្រឡប់មកវិញដោយសុវត្ថិភាពព្រមទាំងបានប្រគល់សម្បត្តិទាំងអស់ដែលចំណេញពីជំនួញជូនលោកស្រីទាំងអស់ ។

**☪-អាពាហ៏ពិពាហ៏មូហាំម៉ាត់ជាមួយលោកស្រីខឌីជះ**

ក្រោយពីលោកស្រីបានឃើញនូវភាពឈ្លាសវៃនិងស្មោះត្រង់របស់មូហាំម៉ាត់ព្រមទាំងការរៀបរាប់របស់មៃសារ៉ស់ពីអ្វីដែលគាត់បានឃើញផ្ទាល់នូវសកម្មភាពដែលពោរពេញទៅដោយភាពថ្លៃថ្នូរ ស្មោះត្រង់និងមានប្រសិទ្ធិភាពក្នុងការធ្វើជំនួញរបស់មូហាំម៉ាត់មក ធ្វើអោយលោកស្រីមានចំណាប់អារម្មណ៏ និងទំនុកចិត្តលើមូហាំម៉ាត់ ។ ក្នុងអំឡុងពេលមូហាំម៉ាត់កំពុងធ្វើជំនួញនៅស្រុកស្ហាមមានមនុស្សម្នាខ្លះបានលាន់ម៉ាត់ថាៈ" មានភាពចំឡែកខុសពីធម្មតាខ្លះបានបង្ហាញអោយពួកគេឃើញដូចជាមានម៉ាឡើអ៊ីកាហ៏ពីរនាក់បាំងជាម្លប់លើលោកក្នុងពេលព្រះអាទិត្យកំពុងបញ្ចេញកំដៅខ្លាំង" ។ លោកស្រីខឌីជះជាប់ចិត្តស្រលាញ់និងទុកចិត្តបំផុតលើបុគ្គលមូហាំម៉ាត់ ។ បន្ទាប់មកលោកស្រីបានប្រើមនុស្សជំនិតម្នាក់របស់លោកស្រីទៅជួបមូហាំម៉ាត់ ដោយបង្ហាញពីបំណងចង់រៀបការជាមួយមូហាំម៉ាត់ ។ មូហាំម៉ាត់ក៏បានយល់ព្រមក្នុងការរៀបការជាមួយលោកស្រី ។ ពេលនោះឪពុកមាទាំងអស់របស់មូហាំម៉ាត់បានចូលស្ដីដណ្ដឹងអ្នកស្រីខឌីជះតាមច្បាប់ ។ រីឯឪពុក



ខាងលោកស្រីខឌីជះឈ្មោះ**អាំរូ កូន អាសាត់**បានឯកភាពយល់ព្រមលើកអ្នកស្រីខឌីជះអោយមូហាំម៉ាត់ ។ អ្នកដែលបានចូលរួមក្នុងពិធីនេះមានវង្សត្រកូលហ៊ើស្ហិម និងមេដឹកនាំពួកអារ៉ាប់គូរ៉ៃស្សជាច្រើននាក់ទៀតដោយបានឯកភាពលើប្រាក់ខាន់ស្លានូវចំនួនដ៏សមរម្យ ។អ្នកសូត្រឃុតហ្ពះនីកះ[១] ពេលនោះគឺអាហ្ពូតលិបជាឪពុកមារបស់ណាហ្ពី ។ ក្រោយមកលោកបានសូត្ររៀបរាប់ប្រវត្តិវង្សត្រកូលនិងភាពថ្កុំថ្កើងរបស់ណាហ្ពី ។អាពាហ៏ពិពាហ៏រវាងណាហ្ពី និងអ្នកស្រី ខឌីជះ បានបញ្ចប់បន្ទាប់ពីណាហ្ពីវិលត្រឡប់មកពីស្រុកស្ហាមរយៈពេលជាងពីរខែ ។ សូមបញ្ជាក់ផងដែរថាខណៈពេលនោះណាហ្ពីទើបមានអាយុ ២៥ឆ្នាំ រីឯអ្នកស្រីខឌីជះវិញ មានអាយុ ៤០ឆ្នាំ ។ មានមតិខ្លះបាននិយាយថាពេលនោះណាហ្ពីមានអាយុ២៨ឆ្នាំ ។តែមតិដែលត្រឹមត្រូវ គឺណាហ្ពីមាន អាយុ ២៥ឆ្នាំ ។

- ស្វាមីទីមួយរបស់អ្នកស្រីខឌីជះមានឈ្មោះ**អាទីកកូនអាអ៊ីហ្សអាល់មិខហ្សូម** គាត់បានទទួលមរណភាព ។
- ស្វាមីទីពីររបស់អ្នកស្រីខឌីជះឈ្មោះ**អាហ្ពូហ៊ើឡះអាត់តៃមី** ។គាត់បានទទួលមរណភាពទៀត ។

ក្រោយមកក៏មានមេដឹកនាំអារ៉ាប់គូរ៉ៃស្សជាច្រើនស្រលាញ់និងព្យាយាមលួងលោមអ្នកស្រីសុំរៀបអាពាហ៏ពិពាហ៏ តែអ្នកស្រីបានបដិសេធមិនយល់ព្រម ។តែអ្នកស្រីបែរជាចាប់ចិត្តស្រលាញ់**មូហាំម៉ាត់**និងយល់ព្រមរៀបការជាមួយតែម្ដង ។ពេលនោះអ្នកស្រីត្រេកអររកអ្វីមកប្រៀបផ្ទឹមពុំបានឡើយដែលបានទទួលមូហាំម៉ាត់ធ្វើជាស្វាមី ។

*១- ឃុតហ្ពះនីកះ :ការថ្លែងសុន្ទរកថាស្ដីអំពីច្បាប់អាពាហ៏ពិពាហ៏*

-អ្នកស្រី **ខឌីជះ** ជាភរិយាទីមួយរបស់ មូហាំម៉ាត់ ដោយអ្នកស្រីមិនអាចមានស្វាមីបន្ទាប់ពីណាហ្គីទៀតឡើយ ។ កូនរបស់ណាហ្គីទាំងអស់គឺមានជាមួយអ្នកស្រីខឌីជះលើកលែងតែ**អ៊ីបរ៉ាហ៊ីម**ម្នាក់គត់ដែលជាកូនរបស់លោកជាមួយខ្ញុំបំរើរបស់លោកឈ្មោះ**ម៉ារីយ៉ាស់អាល់គិបទីយ៉ះ** ។

**☪-កូន៧របស់ណាហ្គីជាមួយអ្នកស្រីខឌីជះមាន**

១- ហ្សៃនាប់

២- រូក័យយ៉ះ

៣- អ៊ុំមូកាល់សូម

៤- ហ្វាទីម៉ះ

៥- អាប់ឌុលឡោះ

៦- កសឹម

កូនប្រុសរបស់ណាហ្គីបានទទួលមរណភាពមុនលោកទាំងអស់លើកលែងតែកូនស្រី៧របស់លោកទេដែលនៅមានជីវិតទាន់សម័យរបស់លោក ។ ពួកនាងក៏បានទទួលមរណភាពមុនណាហ្គីទាំងអស់លើកលែងតែ**ហ្វាទីម៉ះ**ម្នាក់ប៉ុណ្ណោះដែលនៅមានជីវិតបន្ទាប់ពីណាហ្គីបានទទួលមរណៈភាពហើយនាងបានទទួលមរណៈភាពបន្ទាប់ពីមរណៈភាពរបស់ណាហ្គីបានរយៈពេល៦ខែ ។

❁❁❁



## មូហាំម៉ាត់មុនពេលតែងតាំងជារ៉ស៊ូល

ការរស់នៅរបស់មូហាំម៉ាត់តាំងពីកុមារភាព គឺមានប្រាជ្ញាស្មារតីល្អ ខ្លួនប្រាណរឹងមាំ ជ្រះស្អាត លួតលាស់ល្អ ចេះគោរពចាស់ទុំ ។ រូបលោកពោរពេញទៅដោយលក្ខណៈសម្បត្តិល្អប្រសើ ជីវិតថ្លៃថ្នូរ មានក្រមសីលធម៌ សុជីវធម៌ សច្ចភាព មានទំនួលខុសត្រូវ ក្លាហាន យុត្តិធម៌ ស្លូបស្លាត់ ប្រាកដប្រជា មានចិត្តសប្បុរស ទន់ភ្លន់ អត់ធ្មត់ និងមានអំណរគុណ ។ ពិតណាស់លោកស្ថិតក្នុងលំដាប់ខ្ពស់ចំពោះការគោរពប្រតិបត្តិ កត្តញ្ញូ និងចិត្តសប្បុរសធម៌ ។ពិតណាស់អល់ឡោះបានថែរក្សារូបលោកហើយទ្រង់បិទបាំងរូបលោកអំពីប្រការអាក្រក់ដែលមានកើតឡើងក្នុងក្រុមរបស់លោក ។ រូបលោកមិនដែលចូលរួមគោរពសក្ការៈរូបបដិមាអ្វីឡើយ ហើយក៏មិនដែលចូលរួមក្នុងអំពើស៊ីរិក[1] ដែរ ។ លោកមិនដែលទទួលទានអាហារដែលគេបូជាទៅចំពោះអ្វីក្រៅពីអល់ឡោះ ។ លោកនៅឆ្ងាយពីពួកដែលផឹកសុរា និងកន្លែងលេងសប្បាយ រហូតដល់លោកមិនចូលរួមកន្លែងជជែកសប្បាយផងដែរ ។

### ✍សារៈសំខាន់ក្នុងជំពូកនេះ

**នៅក្នុងជំពូកនេះបានបង្ហាញនូវសារៈសំខាន់យ៉ាងច្រើនក្នុងនោះមានដូចជា:**

- ណាហ្គីមូហាំម៉ាត់ មានកំណើតក្នុងត្រកូលខ្ពង់ខ្ពស់ក្នុងចំណោមប្រជាជន

---

*១ -ស៊ីរិក : ពហុទេពនិយម*

អារ៉ាប់ ។

- មូហាំម៉ាត់ជារ៉ស៊ូលដែលមានឧត្តមភាពជាងគេក្នុងចំណោមបណ្ដារ៉ស៊ូលទាំងអស់ ។
- មូហាំម៉ាត់ ជាមនុស្សលោក ដែលអល់ឡោះជ្រើសតាំងជារ៉ស៊ូលសំរាប់មនុស្សលោកទូទៅ ។
- មូហាំម៉ាត់ជារ៉ស៊ូលចុងក្រោយ ដោយគ្មានរ៉ស៊ូលបន្ទាប់ពីលោកឡើយ ។
- ឧត្តមភាពនៃហ្ពៃទិលឡើសអាល់ហារ៉ម ។
- អល់ឡោះការពារកាក់ហ្ពះ និង ទឹកដីដ៏ពិសិដ្ឋ ។
- រ៉ស៊ូលុលឡោះត្រូវបានអល់ឡោះការពារពីអំពើអាក្រក់ និងអំពើស៊ីរិក តាំងពីមុនតែងតាំងលោកជារ៉ស៊ូល ។
- គ្រប់បណ្ដារ៉ស៊ូលតែងធ្លាប់ជាអ្នកគង្វាលសត្វ ។
- អ៊ីស្លាមអនុញ្ញាតអោយធ្វើពាណិជ្ជកម្មដើម្បីជីវភាព ។
- ភាពស្មោះត្រង់ និង ការទទួលខុសត្រូវនាំមកនូវភាពជោគជ័យ ។



# **ជំពូកទី២**

## **មូហាំម៉ាត់ក្លាយខ្លួនជាណាហ្ពីនិងការអំពាវនាវ**

ដូចបានបញ្ជាក់កន្លងមកហើយពីភាពអពមង្គលនិងការទំនាក់ទំនងរវាងណាហ្ពីនិងក្រុមរបស់លោកដែលនាំអោយមានការបង្កឡើងកាន់តែអាក្រក់ហើយបង្កនូវភាពចលាចល តាមការយល់ឃើញរបស់ពួកគេមកលើណាហ្ពីជាហេតុនាំអោយមានភាពអពមង្គល និងវិនាសអន្តរាយ ។

ណាហ្ពីមានបំណងដកខ្លួនចេញអោយឆ្ងាយពីពួកគេហើយទៅរកទីកន្លែងដែលអាថិកំបាំង និងស្ងប់ស្ងាត់ជាមួយនឹងការគិតធ្វើយ៉ាងណាដើម្បីរំដោះពួកទាំងនោះអោយចាកផុតពីភាពងងឹតនិងភាពអន្តរាយ ។ ភាពចលាចលបង្កកាន់តែធ្ងន់ធ្ងរឡើងៗ ។ ណាហ្ពីមូហាំម៉ាត់ក៏ចាប់ផ្ដើមចូលទៅស្នាក់នៅក្នុងរូងភ្នំមួយឈ្មោះថា "ហ៊ីរ៉ក" ក្នុងគោលបំណងដើម្បីគោរពសក្ការៈចំពោះអល់ឡោះដោយប្រតិបត្តិតាមគោលការណ៍សាសនាណាហ្ពីអ៊ីបរ៉ហ៊ីមដែលលោកបានបន្សល់ទុក ។លោកចូលទៅក្នុងរូងភ្នំនោះជារៀងរាល់ឆ្នាំនៅខែរ៉ម៉ាដន ( ខែទី៩ នៃ មូហាំម៉ាត់សករាជ) ។

នៅពេលដែលលោកបានបំពេញនូវការគោរពចំពោះអល់ឡោះនៅទីនោះរយៈពេលមួយខែហើយ លោកក៏ធ្វើដំណើរទៅកាន់ម៉ាក្កះនាពេលព្រឹក ។ ក្រោយមកលោកក៏ដើរតវ៉ាហ្វ[១] ជុំវិញកាក់ហ្ពះ ក្រោយមកក៏វិលទៅលំនៅ

*១ - តវ៉ាហ្វ : គឺជាការដើរព័ទ្ធជុំវិញកាក់ហ្ពះ*

ដ្ឋានរបស់លោកវិញ។ លោកអនុវត្តបែបនេះរយៈពេល ៣ ឆ្នាំ។ នៅពេលលោកមានអាយុគំរប់៤០ឆ្នាំជាធម្មតាកាលណាបណ្តារ៉ស៊ូលដែលអល់ឡោះចាត់តាំងក្លាយជារ៉ស៊ូលគឺនៅពេលគំរប់វ័យនេះទាំងអស់ ហើយក៏ចាប់ផ្តើមចេញជាសញ្ញាជាណាហ្ពីនិងការផ្តល់ពតិមានរីករាយក្នុងពេលនោះផងដែរ។ លោកបានសុបិន្តឃើញកិច្ចការល្អហើយក៏បានកើតឡើងពិតប្រាកដមែនដូចជាលោកសុបិន្តឃើញពន្លឺពណ៌សនិងលឺសំលេងដង្ហោយហៅលោក ។លោកមានប្រសាសន៏ថាៈ " ជាការពិតខ្ញុំបានដឹងយ៉ាងច្បាស់ថានៅក្នុងរូងភ្នំនៅឯម៉ាក្កះគឺមានសំលេងសាឡាម[១] មកលើរូបខ្ញុំមុនពេលខ្ញុំក្លាយជារ៉ស៊ូល "។

## ☪ -ការចាប់ផ្តើមក្លាយជាណាហ្ពី និងការបញ្ចុះវ៉ាហ៊ី



នៅក្នុងខែរ៉ម៉ាដន ឆ្នាំទី៤១ នៃអាយុរបស់ណាហ្ពីគឺលោកបានចូលទៅ ក្នុងរូងភ្នំហ៊ីរ៉ក[២] ដើម្បីគោរពសក្ការៈ ហ្ស៊ីកៀរ[៣] ចំពោះអល់ឡោះស្រាប់តែជីប៊រ៉អ៊ីលបានមកជួបលោកដោយនាំពតិមានថាលោកជាណាហ្ពីនិងទទួល វ៉ាហ៊ីអំពីអល់ឡោះ ។

អាអ៊ីស្ហះបានមានប្រសាន៏ថា ណាហ្ពីតែងចូលចិត្តចូលទៅក្នុងរូងភ្នំតែម្នាក់ឯង ដើម្បីគោរពសក្ការៈចំពោះអល់ឡោះ។ ខណៈនោះម៉ាឡើអ៊ីកាហ៏

*១ - សាឡាម :វន្ទនាការ . បដិសណ្ឋារកិច្ច ។*

*២ - ហ៊ីរ៉ក :ជារូងមួយនៅភ្នំសួរ ។*

*៣- ហ្ស៊ីកៀរ :ការសូត្រធមិដើម្បីការលើកតំកើង និងការសរសើរចំពោះអល់ឡោះ ។*



បានមកជួបណាហ្ពី ហើយពោលទៅកាន់ណាហ្ពីថា ឱ! មូហាំម៉ាត់ ចូរអ្នកសូត្រ។ ណាហ្ពីឆ្លើយថាៈ ខ្ញុំមិនចេះសូត្រទេ។ ម៉ាឡើអ៊ីកាហ៏បានប្រើអោយណាហ្ពីសូត្រ ហើយលោកឆ្លើយយ៉ាងនេះចំនួន៣ដង។ បន្ទាប់មកជីប៊រ៉អ៊ីលក៏សូត្រដែលមានន័យថាៈ"ឱ!មូហាំម៉ាត់ចូរអ្នកសូត្រនូវនាមម្ចាស់របស់អ្នកដែលបានបង្កើតអ្នក។ ទ្រង់បានបង្កើតមនុស្សលោកអំពីដំណក់ឈាម។ ចូរអ្នកសូត្រចំពោះនាមម្ចាស់របស់អ្នកដ៏មហាខ្ពង់ខ្ពស់។ ទ្រង់ជាអ្នកបង្រៀនពួកគេអោយចេះតាមរយៈប៊ិច ហើយបង្រៀនមនុស្សនូវអ្វីដែលពួកគេមិនទាន់ចេះដឹង"។ ពេលនោះណាហ្ពីភ័យញាប់ញ័រទាំងក្តីក្តុកក្តួលក្នុងចិត្តហើយបាននិយាយទៅកាន់ភរិយារបស់លោក (អ្នកស្រីខឌីជះ) ថាៈ សូមអ្នកជួយគ្របដណ្តប់ភួយអោយខ្ញុំ។ លោកស្រីក៏យកភួយមកគ្របរហូតដល់មានភាពកក់ក្តៅឈប់ភ័យខ្លាច។ ក្រោយមកលោកក៏បានពិពណ៌នាពីព្រឹត្តិការណ៏ទាំងនោះប្រាប់ដល់អ្នកស្រីខឌីជះ ។អ្នកស្រីក៏មានប្រសាសន៏ថាវាពុំដូចនោះទេ។ ខ្ញុំសូមស្បថចំពោះអល់ឡោះថាទ្រង់មិនធ្វើបាបលើរូបលោកជាដាច់ខាត។ លោកជាអ្នកល្អបរិសុទ្ធជាអ្នកផ្សារភ្ជាប់សាច់សាលោហិតជាអ្នកជួយដល់គេក្នុងគ្រាមានអាសន្នជាអ្នកផ្តល់ជីវភាពដល់អ្នកក្រីក្រនិងជាអ្នកទទួលរាក់ទាក់ចំពោះភ្ញៀវ ។ល។

ក្រោយមកអ្នកស្រីក៏បាននាំណាហ្ពីទៅជួបជាមួយនឹងបងប្អូនជីដូនមួយរបស់អ្នកស្រីឈ្មោះវ៉ារ៉កោះដែលជាអ្នកនិពន្ធ និងជាសាស្ត្រាចារ្យនិពន្ធគម្ពីរអ៊ីប៊រ៉នីនិងជាព្រឹទ្ធាចារ្យដែលពិការភ្នែក។ អ្នកស្រីក៏ប្រាប់ទៅវ៉ារ៉កោះអំពី

មូហាំម៉ាត់  ហើយវ៉ារ៉ាកោះក៏បានសួរមូហាំម៉ាត់ពីរឿងហេតុដែលកើតឡើងថា ” តើលោកបានឃើញអ្វីខ្លះ?  រ៉ស៊ូលុលឡោះក៏និយាយរឿងហេតុទាំងអស់ ។វ៉ារ៉ាកោះឆ្លើយថា ” នេះគឺជាសញ្ញាមួយដែលអល់ឡោះបានបញ្ចុះមកលើមូសាដែរ ” ។ ពិតណាស់មូហាំម៉ាត់ចាប់ផ្តើមកើតជាណាហ៊្ពីនិងរ៉ស៊ូលនៅថ្ងៃទី ២១ ខែរ៉ម៉ាដនឆ្នាំទី ៤១ នៃអាយុរបស់លោក ដែលជាព្រឹត្តិការណ៍ដ៏អស្ចារ្យនៃរាត្រីឡៃឡើទុលកឌើរ[1] ផងដែរហើយត្រូវនឹងថ្ងៃទី ១០ខែសីហាឆ្នាំ ៦១០នៃ គ.ស ពោលគឺ អាយុរបស់លោកគំរប់ ៤០ ឆ្នាំ៦ ខែ ១០ថ្ងៃ ។

បន្ទាប់ពីមានវ៉ាហ៊ីបញ្ចុះជាលើកដំបូងមកវាក៏ត្រូវបានឈប់ទៅវិញជាច្រើនថ្ងៃ ។ព្រឹត្តិការណ៍នេះធ្វើអោយណាហ៊្ពីមានការព្រួយបារម្ភ និងឈឺចាប់បំផុត ។ តែវាក៏ជាការប្រសើរដែរដែលបានធ្វើអោយលោកបានវិលត្រឡប់ទៅរកស្ថានភាពដើមវិញ ។ ជាការពិតណាស់ ណាហ៊្ពីបានវិលត្រឡប់ទៅរូងភ្នំហ៊ីរ៉ាកវិញដើម្បីបំពេញកិច្ចការដែលមិនទាន់បញ្ចប់ពីខែរ៉ម៉ាដន ហើយនៅពេលបញ្ចប់លោកក៏វិលទៅម៉ាក្កះវិញដូចគ្រាមុន ។

ណាហ៊្ពីបានមានប្រសាសន៍ថានៅពេលដែលខ្ញុំធ្វើដំណើរឆ្លងកាត់ជ្រលងអូរស្រាប់តែមានសំលេងស្រែកហៅខ្ញុំ  តែពេលខ្ញុំងាកមើលជុំវិញខ្លួនរបស់ខ្ញុំពុំមានឃើញអ្វីទាំងអស់ ។ពេលខ្ញុំមើលទៅលើ   ស្រាប់តែឃើញស្រមោលអ្វីមួយមិនច្បាស់ ។ ពេលនោះមានម៉ាឡើអ៊ីកាហ៍ម្នាក់បានមកដល់រូងភ្នំហ៊ីរ៉ាក

*១-រាត្រីឡៃឡើទុលកឌើរ : រាត្រីមួយដ៏អស្ចារ្យបំផុតដែលទទួលបានផលបុណ្យស្មើមួយពាន់ខែ ។*



ដោយគេអង្គុយលើកៅអី ក្នុងលំហអាកាសចន្លោះផែនដីនិងមេឃ ។ ពេលនោះធ្វើអោយខ្ញុំភ័យយ៉ាងខ្លាំង ។ ខ្ញុំរត់ទៅផ្ទះជួបខឌីជះ ដោយអោយនាងគ្របដណ្តប់ភួយអោយខ្ញុំ  ហើយស្រោចទឹកត្រជាក់ដាក់ខ្ញុំផងដែរ ។ ខណៈនោះអល់ឡោះបានបញ្ចុះជំពូកអាល់មុដហ្ហើសសៀរ(المدثر) ។   នៅក្នុងជំពូកនេះបង្ហាញថា :

១-ការកំណត់មកលើណាហ៊្ពីឱ្យផ្តល់ពតិមាន  និងព្រមានដល់មនុស្សលោកអោយគោរពកោតខ្លាចចំពោះអល់ឡោះ    ហើយបោះបង់នូវបណ្តាជំនឿផ្សេងៗដែលនាំអោយអន្តរាយដល់ខ្លួន ។

២-កំណត់អោយណាហ៊្ពីទទួលរាល់បទបញ្ជារបស់អល់ឡោះអំណត់អត់ធ្មត់ដើម្បីបំពេញបេសកកម្មរបស់ខ្លួននិងស្វែងរកភក្តីភាព ការសណ្តោសប្រណីពីអល់ឡោះនិងដើម្បីក្លាយខ្លួនជាគំរូល្អដល់អ្នកមានជំនឿចំពោះអល់ឡោះ ។

៣-ត្រូវលើកដំកើងអល់ឡោះជាម្ចាស់តែមួយគត់ដោយមិនស្ទ៊ីរកចំពោះទ្រង់ឡើយព្រមទាំងការព្យាយាមសំអាតខ្លួនប្រាណឱ្យបានល្អទាំងរូបសម្បត្តិនិងចរិយាសម្បត្តិ ។

## ☪ -រូបភាពនៃការបញ្ចុះវ៉ាហ៊ី

វ៉ាហ៊ីបានបញ្ចុះជាបន្តបន្ទាប់ក្នុងរូបភាពដូចខាងក្រោម :

១- កាយល់សប្តិយ៉ាងពិតប្រាកដ ។

២- វ៉ាហ៊ីដែលនាំមកដោយជីបរ៉អ៊ីលដែលបានបញ្ចូលទៅក្នុងចិត្តរបស់ណាហ៊្ពីមូហាំម៉ាត់ ។

ជីប្រ៊ីលតែងខ្លួនជាបុរសម្នាក់មកជួបណាហ្ពីមូហាំម៉ាត់ដោយបាន សន្ទនាជាមួយគ្នា ។

៣- វ៉ាហ៊ីបានបញ្ចុះមកដល់ណាហ្ពីហាក់ដូចជាស្នូរសំលេងជួង ។

៤- ណាហ្ពីបានមើលឃើញម៉ាឡើអ៊ីកាហ៍នូវរូបរាងពិតដែលអល់ឡោះបានបង្កើត ។

៥- អល់ឡោះបានផ្តល់វ៉ាហ៊ីនោះមកអោយណាហ្ពី ក្នុងពេលលោកនៅលើមេឃានារាត្រីមៀករ៉ាច ។

៦- ការមានបន្ទូលផ្ទាល់ពីអល់ឡោះ មកកាន់ណាហ្ពីមូហាំម៉ាត់ដោយគ្មានតាមរយៈម៉ាឡើអ៊ីកាហ៍ ។

## ☪-បេសកកម្មនៃការអំពាវនាវ

### ក-ការអំពាវនាវជាសំងាត់

នៅពេលដែលអល់ឡោះបានបញ្ចុះវាក្យខណ្ឌទាំងនេះរ៉ស៊ូលបានបំពេញបេសកកម្មរបស់ខ្លួនដោយអនុវត្តតាមបទបញ្ជារបស់អល់ឡោះក្នុងការអំពាវនាវមនុស្សអោយទទួលស្គាល់អល់ឡោះតែមួយ ។ជាការពិតណាស់អល់ឡោះផ្តល់លទ្ធភាពដល់ណាហ្ពី ក្នុងការចាប់ផ្តើមអំពាវនាវដោយលោកចាប់ផ្តើមនូវការអំពាវនាវជាសំងាត់ពោលគឺលោកចាប់ផ្តើមចំពោះក្រុមគ្រួសារសាច់សាលោហិតនិងមិត្តភក្តិរបស់លោក ។ ក្នុងការអំពាវនាវជំហានដំបូងនេះគឺលោកចាប់ផ្តើមចំពោះជនណា ដែលអល់ឡោះបានកំណត់សំរាប់គេជ្រើសរើសមាគ៌ាដែលនាំឆ្ពោះទៅរកសុភមង្គលប៉ុណ្ណោះ ។ នៅក្នុងដំណាក់កាល



នេះមានដូចជា :

១-អ្នកមានជំនឿមុនគេបង្អស់សំរាប់ស្ត្រីគឺលោកស្រីខឌីជះជាភរិយារបស់លោកដែលជាអ្នកដឹងរាល់ព្រឹត្តិការណ៍ដែលកើតមានចំពោះលោក ។

២- ណាហ្ពីបានប្រញាប់ប្រញាល់ទៅជួបមិត្តសំលាញ់របស់គាត់ ហើយពណ៌នាពីអ្វីដែលអល់ឡោះបានលើកតំកើងលោក ជាណាហ្ពីនិងជារ៉ស៊ូល ព្រមទាំងបង្ហាញរាល់ព្រឹត្តិការណ៍ដែលបានកើតឡើង ។ ខណៈនោះអាហ្ពូហ្កើតកើរមានជំនឿភ្លាមដោយឥតសង្ស័យអ្វីឡើយ ។ដូចនេះគាត់គឺជាអ្នកមានជំនឿមុនគេផ្នែកខាងបុរស ។

៣- ក្មេងដែលមានជំនឿលើណាហ្ពីមុនគេបង្អស់គឺអាលី កូនអាហ្ពូតលិប ។ អាលីគឺជាក្មេងម្នាក់ដែលណាហ្ពីចិញ្ចឹមថែរក្សា និងទទួលខុសត្រូវគ្រប់បែបយ៉ាង ។ នៅពេលដែលអាលីមានអាយុ១០ឆ្នាំ គាត់តែងបានធ្វើដំណើរជាមួយណាហ្ពីលើគ្រប់កិច្ចការទាំងអស់ ហើយនៅពេលណាហ្ពីអំពាវនាវគាត់អោយយល់ពីអ៊ីស្លាមគាត់ក៏ជឿភ្លាម ។ ចំនែកឯអ្នកមួយចំនួនទៀតដូចជា **តល់ហះសាក់ឌីអាប់ឌុររ៉ស់ម៉ាន** ក៏ត្រូវបានអាហ្ពូហ្កើតកើរពន្យល់ណែនាំអំពីអ៊ីស្លាមហើយក៏បាននាំពួកគេឱ្យទៅជួបណាហ្ពីផងដែរ ។ បន្ទាប់មកពួកគេក៏ទទួលយកសាសនាអ៊ីស្លាមដោយគេទាំង ៣នាក់ជាប្រជាជនដ៏ស្មោះត្រង់ ហើយពួកគេក៏ចាប់ផ្តើមអំពាវនាវដល់អ្នកដទៃទៀត ។ ពួកគេក៏បានចូលជាអ៊ីស្លាមជាបន្តបន្ទាប់ដែរ ។

ការទទួលស្គាល់សាសនាអ៊ីស្លាមថ្មីៗនោះពួកគេមិនទាន់បានដឹងច្បាស់លាស់

ពីការគោរពចំពោះអល់ឡោះឡើយ ។បទបញ្ញត្តិទាំងឡាយរបស់អ៊ីស្លាមក៏ត្រូវបានបញ្ចុះជាបន្តបន្ទាប់ ក្រោយពីបញ្ចុះវ៉ាហ៊ីនូវវាក្យខណ្ឌកន្លងមក ។ ទាំងនេះគឺដើម្បីបង្ហាញ និងបញ្ជាក់ដល់ពួកគេអោយបានយល់ដឹងអំពីតំលៃនៃសាសនានិងការមានជំនឿចំពោះអល់ឡោះ ដើម្បីអោយពួកគេសំអាតខ្លួនប្រាណព្រមទាំងកែប្រែអត្តចរិតដោយប្រកាន់នូវក្រមសីលធម៌និងសុជីវធម៌ថ្លៃថ្នូរ ។

ការអំពាវនាវជាសំងាត់របស់ណាប៊ីរយៈពេលបីឆ្នាំ ។ក្រោយមកក៏បានលេចលឺដំណឹងនេះដល់ពួកគូរ៉ៃស្ស ហើយពួកគេក៏បានរារាំងណាប៊ីនិងអ្នកមានជំនឿតែពុំមានជាលក្ខណៈចំហនោះទេ ដោយសារថាណាប៊ីមិនដែលប្រឆាំង ឬមើលងាយដល់សាសនារបស់ពួកគេឡើយ ។

**ខ-ការអំពាវនាវដោយចំហ**

**☪- ការអំពាវនាវចំពោះសាច់សាលោហិត**

បន្ទាប់ពីរ៉សូលបានអំពាវនាវជាសំងាត់អស់រយៈពេលពីរឆ្នាំមកឃើញថារ៉សូលមានការពេញចិត្ត មានទំនុកចិត្ត និងមានពួកគូរ៉ៃស្សជាច្រើនជួយគាំទ្រលើកទឹកចិត្ត ហើយលោកក៏បានត្រៀមលក្ខណៈនិងមធ្យោបាយជាច្រើនសំរាប់ប្រតិបត្តិការអំពាវនាវមនុស្សអោយទទួលស្គាល់អ៊ីស្លាម ។

ណាប៊ីមូហាំម៉ាត់បានធ្វើការអំពាវនាវដល់ក្រុមគ្រួសារសាច់សាលោហិតរបស់លោកមានដូចជា វង្សត្រកូលហាស៊ីម និងកូនចៅនៃវង្សត្រកូលរបស់អាប់ឌុលមូតល់លិប ។មានមនុស្សជាច្រើនបាននិយាយអំពីពាក្យសំដីដ៏ផ្អែមល្ហែមទន់ភ្លន់របស់ណាប៊ីលើកលែងតែឪពុកមាររបស់ណាប៊ីគឺអាប៊ូឡើហាប់



ប៉ុណ្ណោះបាននិយាយនូវពាក្យសំដីអាក្រក់ពីរ៉សូល ហើយពុំមានជំនឿ ថែមទាំងប្រឆាំងរារាំងដល់ការអំពាវនាវរបស់ណាប៊ីទៀតផង ។

**☪ -នៅលើភ្នំសហ្វា**



នៅថ្ងៃមួយរ៉សូលុលឡោះ[១] បានធ្វើដំណើរឡើងទៅលើភ្នំសហ្វាដោយលោកឈរលើថ្មខ្ពស់មួយ ។ បន្ទាប់មកលោកស្រែកនូវឃ្លាមួយដែលបង្ហាញពីការរំលឹក ព្រមាន ប្រកាសប្រាប់ជាដំណឹងអំពីការប្រមូលកំលាំងទ័ព ឬបកាសហេតុអាសន្នដ៏ធំមួយបានកើតឡើង ។ ក្រោយមកលោកបានស្រែកអំពាវនាវថាៈ" ឱ! កូនចៅហ្វាសិរ ឱ!កូនចៅអាត់ឌីឱ!កូនចៅអាប់ឌូម៉ាណាហ្វ ឱ!កូនចៅអាប់ឌុលមូតល់លិប ។ នៅពេលពួកគេបានលឺសំលេងនេះពួកគេបានសួរគ្នាថាតើនរណាស្រែកអី? ពួកគេមួយចំនួនបានឆ្លើយថា គឺមូហាំម៉ាត់ ។ ពេលនោះពួកគេប្រញាប់ប្រញាល់នាំគ្នាធ្វើដំណើរមកជួបណាប៊ី រហូតដល់អ្នកខ្លះមិនអាចមកដោយខ្លួនឯងបានក៏បានបញ្ជូនមនុស្សមកជំនួសដែរ ។នៅពេលពួកគេមកជួបជុំគ្នា ហើយណាប៊ីក៏ចាប់ផ្តើមមានប្រសាសន៍ទៅកាន់ពួកគេអំពីហេតុការណ៍មួយចំនួន ។ ពួកគេទាំងនោះក៏មានជំនឿទាំងអស់ដោយគេយល់ថាណាប៊ីមិនដែលនិយាយកុហកឡើយ ពោលរាល់ពាក្យសំដីរបស់លោក គឺជាការពិត ។ បន្ទាប់មកលោកក៏ចាប់ផ្តើមអំពាវនាវពួកគេ អោយទទួលស្គាល់ កើលីម៉ះស្ហាហាឌះទាំងពីរ[១] ហើយលោកក៏បានបញ្ជាក់បង្ហាញពួកគេនូវខ្លឹមសារនៃប្រយោគ

---

*១- រ៉សូលុលឡោះ :សាហាវីរបស់អល់ឡោះ*

ទាំងពីរនេះ។ បន្ទាប់មកលោកបានរំលឹកដល់ពួកគេ នូវទារុណកម្មរបស់អល់ឡោះ និងមូលហេតុដែលបង្កឱ្យទទួលនូវទារុណកម្ម នេះហើយប្រើអោយពួកគេគោរពកោតខ្លាចចំពោះអល់ឡោះ។

ចំណែកអារ៉ាប់គូរ៉ៃស្សទាំងអស់ហាក់បីដូចជាជួបប្រទះនូវភាពអន្ទះសារ និងភាពរន្ធត់នៅពេលដែលពួកគេជួបប្រទះនូវការចង្អុលបង្ហាញរំលឹកដាស់តឿនពីសំណាក់ណាហ្ពីមក ។ពួកគេមិនមានផ្លូវណាជ្រើសរើសនោះទេ ក៏ប៉ុន្តែនៅពេលដែលពួកគេបានវិលត្រឡប់ទៅកាន់គេហដ្ឋានវិញហាក់ដូចជាមានភាពស្ងប់ស្ងាត់នៅក្នុងខ្លួនរបស់ពួកគេ។ នៅពេលខ្លះ ខណៈពេលដែលណាហ្ពីដើរឆ្លងកាត់ក្រុមរបស់ពួកគេពួកគេមួយចំនួនសើចចំអកដល់ណាហ្ពីទៀតផង។

ចាប់ពីពេលនោះមកណាហ្ពីក៏បន្តការផ្សព្វផ្សាយជាលក្ខណៈចំហ ។លោកសូត្រគម្ពីរអាល់គួរអានបង្ហាញដល់ពួកគេ។ លោកអំពាវនាវដល់ពួកគេដូចអ្វីដែលបណ្តារ៉ស៊ូលមុនៗបានអំពាវនាវដល់ប្រជាជនរបស់គេ។

ណាហ្ពីបានចាប់ផ្តើមគោរពសក្ការៈចំពោះអល់ឡោះនៅមុខពួកគេ។ លោកបានសឡាហ៍[២] នៅក្បែរកាក់ហ្ពះនាពេលថ្ងៃ ហើយពួកគេបានសំលឹងមើលមកណាហ្ពី។ លទ្ធផលនៃការផ្សព្វផ្សាយរបស់ណាហ្ពីពិតជាទទួលបានផ្លែផ្កាដោយមានមនុស្សមួយចំនួនបានចូលសាសនាអ៊ីស្លាមដែលជាសាសនារបស់អល់ឡោះជាបន្តបន្ទាប់។ ដោយឡែកពួកគូរ៉ៃស្សបានខឹងសម្បាររាល់

*១ - កើលីម៉ះស្ហាហ៊ើឌះទាំងពីរ : គឺការទទួលស្គាល់និងធ្វើសាក្សីថាគ្មានទេម្ចាស់ដែលត្រូវគេគោរពពិតប្រាកដមានតែអល់ឡោះ ហើយមូហាំម៉ាត់ជាសាហាវីរបស់ទ្រង់។*

*២ -សឡាហ៍ : កិច្ចគោរពប្រតិបត្តចំពោះអល់ឡោះមួយថ្ងៃមួយយប់ប្រាំដង*



សកម្មភាពរបស់ណាហ្ពី ដោយពួកគេសំលឹងមើលដើម្បីចាប់កំហុសលោកគ្រប់ពេល។ អ្នកខ្លះនិយាយថា ណាហ្ពីជាមនុស្សឆ្កួត ហើយអ្នកខ្លះទៀតនិយាយថា លោកជាមេធ្មប់ជាអ្នកធ្វើអំពើមន្តអាគមជាដើម។ ពួកគេរកគ្រប់មធ្យោបាយដើម្បីវាយប្រហារដល់ណាហ្ពីនិងដើម្បីទប់ស្កាត់ចំពោះការអំពាវនាវនោះ។ សកម្មភាពរបស់ពួកគេមានដូចជា :

១- ការបញ្ឈឺចិត្ត មាក់ងាយ លេងសើច ចំអក ។

២- ការអុកឡុករបស់អ្នកប្រឆាំងចំពោះអ្នកគាំទ្រលើការចង្អុលបង្ហាញរបស់ណាហ្ពីមូហាំម៉ាត់។

៣-ការប្រមូលផ្តុំរបស់ពួកប្រឆាំង ដើម្បីបង្កនូវភាពរឹករវនិងចលាចលទ្វេរដងដល់ណាហ្ពីហើយបាននិយាយថា គម្ពីរអាល់គួរអានគឺជាពាក្យសំដីរបស់មូហាំម៉ាត់ដោយការស្រមើស្រម៉ៃប៉ុណ្ណោះ ។

៤-ការបរិហារកេរ្តិ៍ និងចោទថា លោកជាមនុស្សឆ្កួត មនុស្សវិកលចរិក គ្រូមន្តអាគម អ្នកភូតកុហកជាដើម។

៥- ការសួរដេញដោល ការផ្ចាញ់ផ្ចាល ។ល។

❁❁❁

## ការភៀសខ្លួនទៅកាន់ប្រទេសហាប៉្ហើស្ហះ(អេចូពី )

ពិតណាស់ណាហ្ពីបានណែនាំអោយជនមូស្លីមធ្វើការផ្លាស់ប្តូរទីលំនៅទៅកាន់ហាហ្ពើស្ហះបន្ទាប់ពីបានដឹងដំណឹងយ៉ាងច្បាស់ថា ទីនោះមានស្តេចមួយ

អង្គឈ្មោះណាជើស្ស៊ី គឺជាស្តេចប្រកបដោយយុត្តិធម៌ មិនរំលោភបំពានដល់បុគ្គលណាម្នាក់ឡើយ ។ការធ្វើដំណើរលើកដំបូងរបស់ក្រុមមូស្លីម[1] នេះ នៅក្នុងខែរ៉ក់ជប់[2] ឆ្នាំទី៥នៃការតែងតាំងមូហាំម៉ាត់ជាណាប៊ី ។ក្នុងព្រឹត្តិការណ៍នោះមានចំនួនមនុស្សប្រុសប្រមាណ១២នាក់និងស្រីចំនួន៤នាក់ ។ មេដឹកនាំក្រុមគឺលោក **អូស្មាន កូន អាហ្វាន** ជាមួយភរិយារបស់លោកគឺនាង **រូក័យយ៉ះ**ជាកូនស្រីរបស់ណាប៊ី ។ អ្នកទាំងនោះបានចាកចេញយ៉ាងសំងាត់នៅពេលរាត្រីងងឹតឆ្ពោះទៅកាន់កំពង់ផែស្វូអែប៉ាះខាងត្បូងតំបន់ជុតឌះ ។ ដោយការកំណត់របស់អល់ឡោះ ពួកគេបានជួបទូកឈ្នួលចំនួនពីរគ្រឿង ហើយក៏ជិះរហូតបានដល់ប្រទេសហាប៉ីស្វះ ។ ចំណែកពួកគូរ៉ស្សនៅពេលដឹងដំណឹងនេះ ពួកគេក៏ដេញតាមដោយខឹងយ៉ាងខ្លាំងរហូតដល់មាត់ច្រាំង តែពួកមូស្លីមបានទៅដល់កណ្តាលសមុទ្រទៅហើយ ពោលគឺពួកគេបានទៅដល់ប្រទេសនោះ( ហាប៉ីស្វះ) ដោយសុវត្ថិភាព ។

## ការវិលត្រឡប់ពីប្រទេសហាប៉ីស្វះទៅកាន់ក្រុងម៉ាក្កះវិញ

ពត៌មានដែលថា ពួកមូសរិគីន[3] គូរ៉ស្សបានគោរពចំពោះអល់ឡោះ ជឿចំពោះមូហាំម៉ាត់ជារ៉ស៊ូលរបស់អល់ឡោះ បានលេចលឺដល់ពួកអ្នកភៀសខ្លួនទៅប្រទេសហាប៉ីស្វះទាំងនោះ ។ក៏ប៉ុន្តែវាស្ថិតនៅក្នុងរូបភាពមួយខុសពីការពិតទាំងស្រុង ។ តាមពិតពួកគេបានលឺថា ពួកគូរ៉ស្សបានចូលអ៊ីស្លាម ពួកគេបានវិលត្រឡប់ទៅក្រុងម៉ាក្កះដោយភាពរីករាយ ។ នៅពេលពួកគេបានចូលមកដល់ក្រុងម៉ាក្កះពួកគេក៏បានដឹងពត៌មានពិតប្រាកដ ។ពួកគេមួយចំនួនក៏វិលទៅប្រទេសហាប៉ីស្វះវិញហើយមួយចំនួនទៀតក៏ចូលក្រុងម៉ាក្កះដោយភាពស្ងៀមស្ងាត់ ។

*១ - មូស្លីម : អ្នកដែលកាន់សាសនាអ៊ីស្លាម*
*២ -ខែ រ៉កជប់ : ខែ ទី ៧ នៃ ម.ស*
*៣ -ក្រុមពហុទេពនិយមនៃអំបូរគូរ៉ស្ស*



## ការភៀសខ្លួនទៅកាន់ប្រទេសហាប៉ីស្វះលើកទី២

បន្ទាប់មកពួកមូស្លីមដែលនៅក្រុងម៉ាក្កះនិងអ្នកដែលបានវិលត្រឡប់មកពីប្រទេសហាប៉ីស្វះនោះត្រូវបានទទួលរងនូវការធ្វើទុក្ខបុកម្នេញការដាក់ទណ្ឌកម្ម ការជិះជាន់ពីពួកគូរ៉ស្សព្រោះពួកគេមិនសប្បាយចិត្តដោយបានលឺថាពួកភៀសខ្លួនដែលទៅដល់ប្រទេសហាប៉ីស្វះនោះ ត្រូវបានស្តេចនៃប្រទេសនោះទទួលរាក់ទាក់ស្វាគមន៍យ៉ាងកក់ក្តៅ ។ ដោយសារហេតុផលនិងស្ថានភាពបែបនេះទើបណាប៊ី អនុញ្ញាតអោយប្រជាជនមូស្លីម ធ្វើការភៀសខ្លួនជាលើកទីពីរទៅកាន់ប្រទេសហាប៉ីស្វះ ។ការធ្វើដំណើរលើកទីពីរនេះមានបុរសចំនួន៨៣នាក់និងស្ត្រីចំនួន១៨នាក់ ហើយការធ្វើដំណើរក៏ទទួលរងនូវការលំបាកជាងលើកទីមួយដែរ ។

## ការឃុំឃាំងអំបូរហ៊ើស្ស៊ិមនៅក្នុងជ្រលងភ្នំ

អារ៉ាប់គូរ៉ស្សដែលជាអ្នកប្រឆាំងនឹងរ៉ស៊ូលុលឡោះបានប្រើវិធីស្មោគគ្រោគប្រឆាំងលើរ៉ស៊ូលុលឡោះ និងពួកអ្នកដែលមានជំនឿចំពោះលោកពោលគឺពួកគេបានផ្សំគំនិតគ្នាធ្វើកំណត់ត្រាបោកប្រាស់មួយតំកល់ទុក ។ កំណត់ត្រានោះមានន័យថាៈមិនត្រូវទទួលយកការដោះស្រាយណាមួយជាមួយអំបូរហ៊ើស្ស៊ិមនិងមិនត្រូវមានមនោសញ្ចេតនាជាមួយពួកគេដែរលុះត្រាតែពួកគេព្រមប្រគល់មូហាំម៉ាត់ដើម្បីពួកយើងសំលាប់ចោល ។ ពេលនោះអាហ្ពូតលិបបានបញ្ជាអោយអំបូរហ៊ើស្ស៊ិមចូលទៅក្នុងជ្រលងភ្នំ ។អំបូរហ៊ើស្ស៊ិមរស់នៅទីនោះរយៈពេលបីឆ្នាំ ។អំឡុងពេលនេះការធ្វើទុក្ខបុកម្នេញកាន់តែខ្លាំងឡើងៗព្រមទាំងបានធ្វើការហ៊ុមព័ទ្ធទីផ្សារផងដែរ ។ ពួកគូរ៉ស្សមិនអនុញ្ញាតិអោយទំនិញចូលទីក្រុងម៉ាក្កះដោយងាយនោះទេ ។បើចង់ទិញត្រូវតែប្រញាប់ប្រញាល់ មិនតែប៉ុណ្ណោះគេបានលឺសំលេងទ្រហោយំរបស់ស្ត្រីនិងក្មេងៗពីខាងក្រោយជ្រលងភ្នំដោយសារការស្រេកឃ្លាន ។លើសពីនេះទៅទៀត អ្នកចូលសាសនាអ៊ីស្លាមក៏ត្រូវបានគេធ្វើបាបយ៉ាងខ្លាំងក្លាផងដែរ ។ អាហ្ពូតលិបតែងតែប្រើរ៉ស៊ូលុលឡោះដេកលើគ្រែរបស់លោកដើម្បីលោកជួយការពារអោយកាន់តែមុតមាំថែមទៀតហើយពេលណាមនុស្សម្នាដេកអស់លោកបានប្រើកូនរបស់លោកឬពោះមួយរបស់លោក ឬក៏ក្មួយរបស់លោកណាម្នាក់អោយដេកលើគ្រែរបស់រ៉ស៊ូលុលឡោះវិញ ។



## ផែនការកំទេចកំណត់ត្រាបោកប្រាស់

ក្រោយមកហ៊ីស្ហាមកូនអាំរូដែលជាអ្នកតែងតែលបយកចំណីអាហារទៅអោយអំបូរហ៊ើស្ស៊ិមនៅក្នុងរូងភ្នំពេលយប់ស្ងាត់ បានទៅជួបហ្សូហៃរ៍ កូនអាហ្ពូអ៊ូម៉ៃយ៉ះរួចនិយាយថាៈហ្សូហៃរ៍ ! តើអ្នកនៅសុខដែរឬទេក្នុងពេលដែលអ្នកបានហូបស្រួល ខណៈពេលពោះមួយរបស់អ្នកស្ថិតក្នុងសភាពដូចដែលអ្នកដឹងស្រាប់ហើយនោះ? ហ្សូហៃរ៍បានតបវិញទាំងកំហឹងថាៈ តើឱ្យខ្ញុំធ្វើម្តេចបើខ្ញុំមានតែម្នាក់ឯង?ខ្ញុំសូមស្បថនឹងអល់ឡោះថាៈបើខ្ញុំមានគ្នាម្នាក់ទៀតខ្ញុំច្បាស់ជាក្រោកឡើងកំទេចកំណត់ត្រានោះចោលជាមិនខាន ។ ហ៊ីស្ហាមបន្តថាគឺខ្ញុំ ។ហ្សូហៃរតបទៀតថាៈ តើមានអ្នកទីបីទេ?ហ៊ីស្ហាមប្រាប់ថាគឺអាហ្ពូហ្ពោះទូរី ។ហ្សូហៃរ៍បានសួរថាៈមានអ្នកទីបួនទេ? ហ៊ីស្ហាមប្រាប់ថាគឺហ្សាំអះកូនអាសវ៉ាត់ ។មានអ្នកទីប្រាំទេ? គឺមាន ម៉ាត់អាំកូនអាត់ឌី ។ ហ្សូហៃរ៍បញ្ជាក់ថាៈយើងត្រូវជួបគ្នានៅទីនោះដើម្បីកំទេចកំណត់ត្រានោះចោល ។ហ្សូហៃរ៍បន្តទៀតថាៈ ខ្ញុំជាអ្នកចាប់ផ្តើមមុនគេ ។ ពួកគេបាននាំគ្នាទៅកាក់ហ្ពះលុះពេលទៅដល់ហ្សូហៃរ៍ចាប់ផ្តើមស្រែកឡើងថាៈ ពួកអ្នកស្រុកម៉ាក្កះពួកយើងកំពុងត្រេកត្រអាលនឹងចំណីអាហារ ពួកយើងមានសំលៀកបំពាក់ថ្មី ដោយឡែកអំបូរហ៊ើស្ស៊ិមវិញកំពុងស្ថិតក្នុងក្តីអន្តរាយ ខ្ញុំសូមស្បថនឹងអល់ឡោះចុះថាៈខ្ញុំនឹងមិនអង្គុយចុះទេ លុះត្រាតែកំណត់ត្រាបោកប្រាស់នោះត្រូវកំទេចចោល ។ពេលនោះអាហ្ពូជើហ៊ិលស្រែកឡើងថាៈខ្ញុំសូមស្បថនឹងអល់ឡោះគឺវានឹងមិនត្រូវគេកំទេចឡើយ ។ ពេលនោះ ហ្សាំអះ បាន

និយាយទៅកាន់អាហ្គូដើហ៊ុលថាៈ រូបអ្នកគឺជាមេបោកប្រាស់ ពួកយើងមិនបានយល់ព្រមចំពោះកំណត់ត្រាបោកប្រាស់ នៅពេលពួកអ្នកកត់ត្រានោះទេ។ អាហ្គូហ្គោះទូរីបានពោលឡើងបន្ទាប់ពីហ្សាំអះថាៈ គឺពិតជាត្រឹមត្រូវព្រោះពួកយើងពិតជាមិនយល់ព្រមចំពោះអ្វីៗដែលពួកអ្នកបានកត់ត្រានោះឡើយ។ ម៉ាត់អាំកូនអាត់ឪបាននិយាយគាំទ្រថាបុគ្គលណាហើយដែលនិយាយផ្ទុយពីនេះគឺពិតជាអ្នកភូតកុហក។ ពេលនោះហ៊ីស្ហាមកូនអាំរូក៏និយាយដូចនោះដែរ។ ពេលនោះអាហ្គូដើហ៊ុលបានតបថាៈការងារនេះត្រូវបានសំរេចរួចរាល់ហើយ គឺដោយបានពិភាក្សាគ្នានៅពេលយប់ក្រៅពីកន្លែងនេះ។ អល់ឡោះបានផ្តល់ដំណឹងដល់រ៉សូលរបស់ទ្រង់គឺលោកមូហាំម៉ាត់កូនអាប់ឌុលឡោះ ពីការដែលទ្រង់លុបចោលនូវនាមដ៏ស្អាតស្អំរបស់ទ្រង់ ដែលពួកគូរ៉ស្សបានសរសេរក្នុងកំណត់ត្រានោះដោយទ្រង់បន្សល់ទុកតែប្រការស៊ីរិកនិងកិច្ចការបំពានផ្សេងៗប៉ុណ្ណោះ។ ណាហ្គីបានប្រាប់រឿងនេះដល់មារបស់លោកអាហ្គូតលិប តែអាហ្គូតលិបមិនទាន់ជឿទេ ហើយលោកក៏ធ្វើដំណើរទៅកាក់ហ្គះ។ ពេលពួកគូរ៉ស្សបានឃើញអំបូរហ៊ើស្ហុម ច្រើនបានចេញពីជ្រលងភ្នំបែបនេះ ពួកគេនឹកស្មានថាៈពួកនេះព្រមប្រគល់មូហាំម៉ាត់អោយពួកគេវិញហើយព្រោះដោយសារតែគំនាបលើពួកគេនោះ។ អាហ្គូតលិបក៏ចាប់ផ្តើមនិយាយថាៈ ឥឡូវនេះរវាងពួកយើងគឺមានដំណោះស្រាយហើយចូរពួកអ្នកទៅយកកំណត់ត្រារបស់ពួកអ្នកមក ( លោកមិនទាន់ប្រាប់ពួកនោះពីអ្វីដែលមូហាំម៉ាត់ប្រាប់លោកដល់ពួកនោះទេក្រែងពួកនោះមិនព្រម



យកកំណត់ត្រានោះមក) អាហ្គូតលិបបានបន្តទៀតថាៈ ពួកយើងទាំងអស់គ្នាត្រូវឈរលើគោលការណ៍ស្មើភាពគ្នាមួយ ពោលគឺក្មួយរបស់ខ្ញុំ ( មូហាំម៉ាត់គេមិនដែលកុហកខ្ញុំទេ ) បានប្រាប់ខ្ញុំថាៈ អល់ឡោះម្ចាស់ទ្រង់ជ្រះស្អាតពីកំណត់ត្រាដែលមាននូវនឹងដៃរបស់ពួកអ្នកនេះ គឺទ្រង់បានលុបចេញនូវនាមរបស់ទ្រង់ដែលមាននៅក្នុងកំណត់ត្រានេះ ហើយទ្រង់បានរក្សាទុកល្បិចកលនិងការកាត់ចំណងសាច់សាលោហិតរបស់ពួកអ្នក ដូចនេះបើសំដីរបស់ក្មួយខ្ញុំពិតប្រាកដមែន គឺពួកយើងនឹងមិនប្រគល់រូបគេអោយទៅពួកអ្នកឡើយរហូតពួកយើងដល់សង្ខាផ្ទុយទៅវិញបើគេនិយាយមិនពិតគឺពួកយើងនឹងប្រគល់រូបគេអោយពួកអ្នកបើពួកអ្នកត្រូវសំលាប់ឬទុកអោយរស់ស្រេចតែពួកអ្នក។ ពួកគូរ៉ស្សតបវិញថា : ពួកយើងយល់ព្រម។ ពួកគេក៏ចាប់ផ្តើមបើកកំណត់ត្រានោះ។ ពេលនោះពួកគេបានឃើញដូចអ្វីដែលមូហាំម៉ាត់បានប្រាប់មែន។ ពេលបានឃើញភាពជាក់ស្តែងដូចនេះ ហើយក្តីក៏ពួកគេនៅតែនិយាយទៅកាន់អាហ្គូតលិបថាក្មួយរបស់អ្នកគឺជាមេធ្មប់ដ៏អាក្រក់បំផុត។

## ឆ្នាំក្រៀមក្រំបំផុត

**១- មរណភាពរបស់អាហ្ពូតលិបៈ** អាហ្ពូតលិបបានធ្លាក់ខ្លួនឈឺធ្ងន់ឡើងៗរហូតសេចក្តីស្លាប់បានមកដល់ ។ ពេលមរណៈភាពជិតឈានមកដល់រ៉ស៊ូលុលឡោះﷺ បានចូលទៅជួបតែនៅទីនោះមានអាហ្ពូជើហ៊ុលនិងអាប់ឌុលឡោះកូនអាហ្ពីអ៊ូម៉ៃយ៉ះ ។ រ៉ស៊ូលុលឡោះﷺបានមានប្រសាសន៏ទៅកាន់អាហ្ពូតលិបថា សូមមាពោលពាក្យថាៈ " គ្មានទេម្ចាស់ដែលត្រូវគេគោរពប្រតិបត្តិដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ ។ ពាក្យនេះខ្ញុំអាចធ្វើជាសាក្សីអោយមានៅចំពោះអល់ឡោះបាន" ។ គ្រាន់តែរ៉ស៊ូលុលឡោះនិយាយចប់អាហ្ពូជើហ៊ុល និងអាប់ឌុលឡោះបាននិយាយទៅកាន់អាហ្ពូតលិបថា តើអ្នកស្អប់សាសនារបស់អាប់ឌុលមូតលលិបឬ? អ្នកទាំងពីរនេះនៅតែបន្តនិយាយរបៀបនេះរហូតដល់អាហ្ពូតលិបពោលនូវពាក្យចុងក្រោយថា"ខ្ញុំស្ថិតនៅក្នុងសាសនាអាប់ឌុលមូតលលិប" ។ ណាហ្ពីﷺបានមានប្រសាសន៏ ថាៈ " ខ្ញុំនឹងព្យាយាមសុំខមាលទោសអោយមាប្រសិនបើខ្ញុំមិនត្រូវបានគេហាមឃាត់ទេនោះ ។អល់ឡោះក៏បានបញ្ចុះនូវបន្ទូលរបស់ទ្រង់ក្នុងជំពូកអាត់តៅហ្ព័តថាៈ

{ما كَانَ للنبِي والذين آمنواْ أَن يستغفرواْ للْمشرِكين ولَو كَانواْ أُولي
قُربى من بعد ما تبين لَهم أَنهم أَصحاب الْجحيمِ }التوبة: 113

មានន័យថាៈ"ណាហ្ពីនិងពួកអ្នកមានជំនឿ គ្មានសិទ្ធិសុំការអធ្យាស្រ័យដល់ពួកមូសរីគីនឡើយ បើទោះបីអ្នកនោះជាថ្នាក់ដឹកនាំជាប់សាច់ជិតយ៉ាងណាក៏ដោយ នេះបើក្រោយពីការបញ្ជាក់ច្បាស់ដល់ពួកគេហើយថាពួកគេជាពួកនរក "។ អល់ឡោះក៏បញ្ជាក់នៅក្នុងបន្ទូលមួយផ្សេងទៀតថា :

( إنك لاَ تهدي من أَحببت ) القصص : 56

មានន័យថាៈ "អ្នក( មូហាំម៉ាត់) ពិតជាមិនអាចបំភ្លឺបង្ហាញដល់អ្នកដែលខ្លួនស្រលាញ់បានឡើយ" ។

ការស្លាប់របស់អាហ្ពូតលិបនៅក្នុងខែរ៉យ៉ប់ឆ្នាំទី១០នៃឆ្នាំតែងតាំងជាណាហ្ពី ។

**២- មរណៈភាពរបស់ខឌីជះ :** រ៉ស៊ូលុលឡោះមិនទាន់បានធូរស្បើយពីក្តីកង្វល់ដោយមូលហេតុមរណភាពរបស់មាលោកផង ស្រាប់តែប្រពន្ធរបស់លោកគឺអ្នកស្រីខឌីជះ បានទទួលមរណភាពទៀតនៅក្នុងខែរ៉ម៉ាដននៃឆ្នាំទី១០ដែរ ពោលគឺក្រោយមរណៈភាពមារបស់លោកចំនួនពីរខែជាងបន្តិចបន្តួច ។ណាហ្ពីﷺបានមានប្រសាសន៏ពីភរិយាជាទីស្រលាញ់របស់លោកថាៈ "ខឌីជះមានជំនឿលើខ្ញុំពេលដែលមនុស្សម្នាប្រឆាំងនឹងខ្ញុំ ។ នាងជឿជាក់លើខ្ញុំពេលដែលមនុស្សម្នាគេភូតកុហក់លើខ្ញុំ ។នាងផ្តល់លុយកាក់អោយខ្ញុំពេលមនុស្សម្នារាំងខ្ទប់លុយពីខ្ញុំហើយអល់ឡោះបានផ្តល់កូនៗអោយខ្ញុំជាមួយនាងនិងទ្រង់មិនបានអោយខ្ញុំមានកូនជាមួយប្រពន្ធផ្សេងឡើយ" ។ ក្រោយពីមា និងប្រពន្ធរបស់ណាហ្ពីបានទទួលមរណៈទៅអា៉រ៉ាប់គូរ៉ស្យបង្កើនការធ្វើទុក្ខបុកម្នេញមកលើលោកនិងអ្នកដែលមានជំនឿកាន់តែធ្ងន់ធ្ងរឡើងៗ ។

**☪ -អាពាហ៏ពិពាហ៏របស់ណាហ្ពីជាមួយសៅឌះបន្ទាប់មកជាមួយអាអ៊ីស្ហះ**

នៅក្នុងខែសៅវ៉ាល់ពោលគឺបន្ទាប់ពីខឌីជះបានទទួលមរណៈភាពមួយ

ខែ  ណាហ្គីបានរៀបការជាមួយសៅឌះកូនស្រីរបស់ហ្សាំអះ ។សៅឌះធ្លាប់រៀបការជាមួយជីដូនមួយនាងគឺលោកស៊ុក់រ៉នហ្គិនអាំរូ ។សៅឌះនិងប្តីរបស់នាងធ្លាប់បានធ្វើដំណើរភៀសខ្លួនទៅហាហ្គើស្ហះដែរ  តែក្រោយពីវិលត្រឡប់មកវិញប្តីរបស់នាងបានស្លាប់ ។ ក្រោយពីរៀបការជាមួយសៅឌះបានមួយឆ្នាំណាហ្គីបានរៀបការជាមួយអាអ៊ីស្ហះក្នុងខែសៅវ៉ាល់ដូចគ្នា ។ ពេលនោះអាអ៊ីស្ហះទើបមានអាយុ៦ឆ្នាំប៉ុណ្ណោះ  លុះពេលនាងមានអាយុ៩ឆ្នាំទើបណាហ្គីយកមកនៅជាមួយជាលក្ខណៈប្តីប្រពន្ធ ។ អាអ៊ីស្ហះជាប្រពន្ធដ៏ជាទីស្រលាញ់បំផុតរបស់ណាហ្គីﷺហើយនាងជាអ្នកមានចំនេះដឹងផ្នែកហ្វីកោះ[១] ជាងប្រពន្ធរបស់ណាហ្គីផ្សេងៗទៀត ។

### ☪ -ការធ្វើដំណើររបស់ណាហ្គីទៅតំបន់តអ៊ីហ្វ

នៅពេលដែលពួកអារ៉ាប់គូរ៉ៃស្សបង្កើនការធ្វើទុក្ខបុកម្នេញមកលើរ៉ស៊ូលុលឡោះនិងបក្សពួករបស់លោក ។ លោកក៏នៅតែបន្តអំពាវនាវមនុស្សឱ្យធ្វើតាមសាសនាអ៊ីស្លាម ។លោកបានចេញដំណើរទៅតំបន់តអ៊ីហ្វជាមួយហ្សៃតកូនហារីសដើម្បីអំពាវនាវអ្នកស្រុកតំបន់នេះអោយចូលអ៊ីស្លាម ។  លោកបានចូលគ្រប់លំនៅដ្ឋានមេដឹកនាំអំពាវនាវពួកគេ និងសុំអោយពួកគេជួយលោកក្នុងការផ្សព្វផ្សាយច្បាប់របស់អល់ឡោះ  តែពួកគេមិនត្រឹមតែមិនជឿ និងមិនជួយលោកទេថែមទាំងធ្វើបាបលោក និងមិត្តភក្តិរបស់លោកផងដែរ ។ ពួកគេបានឈរជាពីរជួរសងខាងផ្លូវរួចយកដុំថ្មគប់ស្រោចមកលើលោកនិងមិត្តភក្តិរបស់លោករហូតធ្វើអោយណាហ្គីរងរបួសជើងចេញឈាម

---

*១-ហ្វីកោះ :ក្រិត្យច្បាប់អ៊ីស្លាម*



ហើយហ្សៃតព្យាយាមការពារណាហ្គីរហូតរបួសក្បាល ។  អ្នកទាំងពីរបានព្យាយាមដើរអោយផុតហ្វូងមនុស្សដែលកំពុងធ្វើបាបលោកដោយមិនដឹងថាខ្លួនដើរទៅទិសខាងណាឡើយ ។ លុះពេលចេញផុតម៉ាឡើអ៊ីកាហ៍ជីប៊រ៉អ៊ីលនិង  ម៉ាឡើអ៊ីកាហ៍ការពារភ្នំមកជួបណាហ្គីហើយជីប៊រ៉អ៊ីលបានហៅណាហ្គីរួចនិយាយថា  "អល់ឡោះបានចាត់តាំងម៉ាឡើអ៊ីកាហ៍ការពារភ្នំអោយមកបំរើអ្នក ចូរអ្នកប្រើគេតាមចិត្តចង់ចុះ" ។ ពេលនោះម៉ាឡើអ៊ីកាហ៍ការពារភ្នំបានអោយសាឡាមទៅណាហ្គី រួចនិយាយថា តាមចំណង់របស់អ្នកមូហាំម៉ាត់ បើអ្នកចង់ ខ្ញុំនឹងលើកភ្នំទាំងពីរ (ភ្នំនៅដីម៉ាក្កះឈ្មោះអាហ្គូហ្គើស) សង្កត់ទៅលើពួកនេះ ។ ណាហ្គីﷺបានឆ្លើយថា: "មិនចាំបាច់ទេ ខ្ញុំសង្ឃឹមថាអល់ឡោះនឹងធ្វើអោយមានអ្នកដែលគោរពសក្ការៈ  ចំពោះអល់ឡោះតែមួយដោយគ្មានស្ហ៊ីរិកនឹងទ្រង់នូវប្រការណាមួយ ចេញពីក្រុមពួកនេះ ។

### ☪ -ព្រឹត្តិការណ៏បំបែកលោកខែ(ព្រះច័ន្ទ)

នៅពេលដែលពួកអារ៉ាប់គូរ៉ៃស្សមិនបានឃើញថាណាហ្គីធ្វើតាមអ្វីដែលពួកគេចង់បាន ពួកគេមានគំនិតមួយថ្មី គឺសំណូមពរដល់មូហាំម៉ាត់អោយបង្ហាញពីភស្តុតាងចំឡែកៗដើម្បីពួកគេផ្ចាញ់ផ្ចាលនិងដើម្បីអោយមនុស្សយល់ថា មូហាំម៉ាត់មិនមែនជាណាហ្គី ។ ពួកគេបានស្នើដល់មូហាំម៉ាត់ថា "តើមាន ភស្តុតាងអ្វីដែលបង្ហាញអោយពួកយើងស្គាល់ថាអ្នកជារ៉ស៊ូល?

ពេលនោះណាហ្គីﷺបានទទូចសុំពីអល់ឡោះអោយទ្រង់បង្ហាញភស្តុតាងដល់ពួកនេះ ។អល់ឡោះបានអោយពួកនេះឃើញលោកខែបែកជាពីរចំនែក មួយចំនែកឃើញនៅលើកំពូលភ្នំអាហ្គូហ្គើស និងមួយចំនែកទៀតឃើញនៅកន្លែងផ្សេង ។ពេលនោះរ៉ស៊ូលុលឡោះមានប្រសាសន៏ថា : "ចូរពួកអ្នក

ធ្វើសាក្សីចុះ ”។ ទោះបីជាបានឃើញបែបនេះហើយក្តី ក៏ពួកនេះនៅតែគ្មានជំនឿដដែលព្រមទាំងនិយាយថានេះជាទង្វើអាបធ្មប់ប៉ុណ្ណោះ”។ មានបុរសម្នាក់បាននិយាយថា:” បើនេះជាអំពើអាបធ្មប់មែននោះគឺគេមិនអាចធ្វើអាបធ្មប់នេះទៅលើមនុស្សទាំងអស់បានទេ ដូចនេះរង់ចាំអ្នកធ្វើដំណើរមកដល់សួរគេពីរឿងនេះ។ លុះពេលមានអ្នកធ្វើដំណើរមកពីតំបន់ឆ្ងាយមកដល់គេបានសួរពីរឿងនេះ។ ពួកគេឆ្លើយថា:ពួកយើងពិតជាបានឃើញមែន ទោះជាពិតយ៉ាងនេះក្តី ក៏អារ៉ាប់គូរ៉ស្សនៅតែមិនជឿលើបុគ្គលមូហាំម៉ាត់ដដែល។

❁❁❁

## ដំណើរអ៊ីសរ៉កនិងមៀករ៉ាច

( **អ៊ីសរ៉ក**គឺការធ្វើដំណើររបស់ណាហ្ពីមូហាំម៉ាត់ពេលរាត្រីពីក្រុងម៉ាក្កះឆ្ពោះទៅវិហារពិសិដ្ឋនៅយេរ៉ូសាលិមប្រទេសបាលីស្ទីន។ **មៀករ៉ាច**គឺដំណើររបស់មូហាំម៉ាត់ឡើងទៅជួបនិងអល់ឡោះនៅសុិតរ៉ទុលមុនតើហ៊ា )។ ចំពោះកាលបរិច្ឆេទនៃព្រឹត្តិការណ៍នេះមានទស្សនៈខុសៗគ្នាតែអ្វីដែលភាគច្រើនប្រកាន់យកនោះគឺវាបានកើតឡើងនៅឆ្នាំទី ១០ នៃឆ្នាំកើតជារ៉ស៊ូលរបស់មូហាំម៉ាត់ ។ដំណើររឿងទាំងស្រុងមានដូចតទៅ: ”ម៉ាឡើអ៊ីកាហ៏ជីបរ៉អ៊ីលបាននាំមកជាមួយនូវសត្វហ្ពើរ៉ក[១] ហើយណាហ្ពីﷺនៅម៉ាស្ជិតហារ៉ម[២] ។

១-ហ្ពើរ៉ក :សត្វមួយប្រភេទស្រដៀងសត្វសេះ។

២-ម៉ាស្ជិតហារ៉ម :វិហារអ៊ីស្លាមដ៏ពិសិដ្ឋមួយកន្លែងនៅក្រុងម៉ាក្កះនៃប្រទេសអារាប៊ីសាអូឌីដ។



ណាហ្ពីមូហាំម៉ាត់បានជិះហ្ពើរ៉កទៅកាន់ហ្ពៃទុលមឹកទិស[១] ដោយមានម៉ាឡើអ៊ីកាហ៏ជីបរ៉អ៊ីលទៅជាមួយដែរ ។លុះពេលទៅដល់ណាហ្ពីបានចងហ្ពើរ៉ករួចចូលទៅក្នុងម៉ាស្ជិត ។នៅទីនោះលោកបានសឡាហ៏ពីររ៉ក៏អាត់ដោយធ្វើជាអ៊ីម៉ាំនៃបណ្តាណាហ្ពីទាំងអស់បន្ទាប់មកម៉ាឡើអ៊ីកាហ៏ជីបរ៉អ៊ីលបានយកថូដាក់ស្រាមួយនិងថូដាក់ទឹកដោះគោមួយ។ ណាហ្ពីបានជ្រើសរើសយកថូដាក់ទឹកដោះគោពេលនោះម៉ាឡើអ៊ីកាហ៏ជីបរ៉អ៊ីលបាននិយាយថា : ”អ្នកបានទទួលយកសាសនាអ៊ីស្លាមហើយអ្នកទទួលបានការចង្អុលបង្ហាញហើយប្រជាជនរបស់អ្នកក៏ដូចគ្នាដែរ តែបើអ្នកជ្រើសរើសយកថូដាក់ស្រាវិញច្បាស់ជាប្រជាជនរបស់អ្នកវង្វេងមិនខាន” ។បន្ទាប់មកម៉ាឡើអ៊ីកាហ៏ជីបរ៉អ៊ីលចាប់ផ្តើមនាំណាហ្ពីពីហ្ពៃទុលមឹកទិសទៅកាន់មេឃជាន់ទី១ ។ជីបរ៉អ៊ីលសុំអោយម៉ាឡើអ៊ីកាហ៏យាមទ្វារមេឃបើកទ្វារ ពេលនោះគេក៏បើកឱ្យ។ នៅមេឃជាន់ទី១ ណាហ្ពីមូហាំម៉ាត់បានឃើញណាហ្ពីអាដាំ ដែលជាឪពុករបស់មនុស្សលោកទាំងឡាយ ។ពេលនោះណាហ្ពីមូហាំម៉ាត់បានឱ្យសាឡាមណាហ្ពីអាដាមបានតបសាឡាមវិញនិងបានពោលពាក្យស្វាគមន៍ហើយទទួលស្គាល់លក្ខណៈជារ៉ស៊ូលរបស់មូហាំម៉ាត់។

បន្ទាប់មកឡើងទៅមេឃជាន់២ជីបរ៉អ៊ីលសុំអោយម៉ាឡើអ៊ីកាហ៏យាមទ្វារមេឃបើកទ្វារ ។ពេលនោះម៉ាឡើអ៊ីកាហ៏នោះក៏បើកអោយ ។នៅមេឃជាន់ទី២ណាហ្ពីមូហាំម៉ាត់បានឃើញណាហ្ពីយ៉ះយ៉ាកូនហ្សាការីយ៉ានិងឃើញណាហ្ពីអ៊ីសាកូនម៉ារីយ៉ាំ។ មូហាំម៉ាត់បានអោយសាឡាមទៅអ្នកទាំងពីរ

១-ហ្ពៃទុលមឹកទិស :វិហារអ៊ីស្លាមដ៏ពិសិដ្ឋនៅយេរ៉ូសាលិមនៃប្រទេសប៉ាលីស្ទីន។

ហើយអ្នកទាំងពីរបានទទួលសាឡាមព្រមទាំងបានស្វាគមន៍និងទទួលស្គាល់លក្ខណៈជារ៉ស៊ូលរបស់មូហាំម៉ាត់។ បន្ទាប់មកឡើងទៅមេឃជាន់ទី៣។ នៅមេឃជាន់ទី៣ណាហ្គីមូហាំម៉ាត់បានឃើញណាហ្គីយូសូហ្វ។ លោកបានអោយសាឡាមណាហ្គីយូសូហ្វ ហើយណាហ្គីយូសូហ្វក៏បានទទួលសាឡាមព្រមទាំងបានស្វាគមន៍ និងទទួលស្គាល់លក្ខណៈជារ៉ស៊ូលរបស់មូហាំម៉ាត់។ បន្ទាប់មកម៉ាឡើអ៊ីកាហ៊ីបាននាំណាហ្គីឡើងទៅមេឃជាន់ទី៤។ នៅមេឃជាន់ទី៤ណាហ្គីមូហាំម៉ាត់បានឃើញណាហ្គីអ៊ីដរីស។ ណាហ្គីមូហាំម៉ាត់បានអោយសាឡាមណាហ្គីអ៊ីដរីស ហើយណាហ្គីអ៊ីដរីសបានទទួលសាឡាមព្រមទាំងបានស្វាគមន៍ និងទទួលស្គាល់លក្ខណៈជារ៉ស៊ូលរបស់មូហាំម៉ាត់។ បន្ទាប់មកបន្តឡើងទៅមេឃជាន់ទី៥។ នៅមេឃជាន់ទី៥ណាហ្គីមូហាំម៉ាត់បានឃើញណាហ្គីហ៊ើរូន។ ណាហ្គីមូហាំម៉ាត់បានអោយសាឡាមណាហ្គីហ៊ើរូន ហើយណាហ្គីហ៊ើរូន បានទទួលសាឡាមព្រមទាំងបានស្វាគមន៍និងទទួលស្គាល់លក្ខណៈជារ៉ស៊ូលរបស់មូហាំម៉ាត់ ។បន្ទាប់មកបន្តឡើងទៅមេឃជាន់ទី៦។ នៅមេឃជាន់ទី៦ណាហ្គីមូហាំម៉ាត់បានឃើញណាហ្គីមូសា។ ណាហ្គីមូហាំម៉ាត់បានអោយសាឡាមណាហ្គីមូសា ហើយណាហ្គីមូសាបានទទួលសាឡាមព្រមទាំងបានស្វាគមន៍និងទទួលស្គាល់លក្ខណៈជារ៉ស៊ូលរបស់មូហាំម៉ាត់ ។ពេលណាហ្គីមូហាំម៉ាត់ដើរផុតណាហ្គីមូសាក៏យំ ។ពេលនោះគេសួរមូសាថា៖ "តើអ្វីទៅដែលធ្វើអោយអ្នកយំ?" ។មូសាឆ្លើយថា៖ "ក្មេងម្នាក់ដែលអល់ឡោះតែងតាំងក្រោយពីខ្ញុំដែលប្រជាជនរបស់គេបានចូលឋានសួគ៌ច្រើនជាងប្រជាជនរបស់ខ្ញុំ" ។បន្ទាប់មកក៏បន្តឡើងទៅមេឃជាន់ទី៧។ នៅមេឃជាន់ទី៧ណាហ្គីមូហាំម៉ាត់បានឃើញណាហ្គីអ៊ីប៉្រហ៊ីម។ ណាហ្គីមូហាំម៉ាត់បានអោយសាឡាមណាហ្គីអ៊ីប៉្រហ៊ីម ហើយណាហ្គីអ៊ីប៉្រហ៊ីមបាន



ទទួលសាឡាមព្រមទាំងបានស្វាគមន៍ និងទទួលស្គាល់លក្ខណៈជារ៉ស៊ូលរបស់មូហាំម៉ាត់។ នៅជាប់នឹងទីនេះមានប៉ៃតុលម៉ាក់មូរ[១] វាជាកន្លែងដែលម៉ាឡើអ៊ីកាហ៊ី៧០ពាន់នាក់ចូលទៅជារៀងរាល់ថ្ងៃ ដោយមិនបានវិលត្រឡប់មកវិញឡើយ ។បន្ទាប់មកណាហ្គីមូហាំម៉ាត់ត្រូវគេយកទៅកាន់ស៊ិតរ៉ទុលមុនតើហ៊ើ[២] រួចគេបញ្ជូនណាហ្គីមូហាំម៉ាត់ទៅជួបអល់ឡោះម្ចាស់។ អល់ឡោះបានដាក់កាតព្វកិច្ចមកលើប្រជាជនមូហាំម៉ាត់នូវសឡាហ៊មួយថ្ងៃមួយយប់ចំនួន៥០ពេល។ ណាហ្គីបានវិលត្រឡប់ចុះមកវិញដើរកាត់មូសាហើយគាត់បានសួរថា៖ "តើម្ចាស់របស់អ្នកបានបញ្ជាដូចម្ដេចខ្លះ?" ណាហ្គីបានប្រាប់ថាគឺប្រើអោយសឡាហ៊៥០ពេលក្នុងមួយថ្ងៃមួយយប់។ មូសាបានប្រាប់ថា៖ "ប្រជាជនរបស់អ្នកគ្មានលទ្ធភាពធ្វើបានទេ អ្នកត្រូវវិលទៅវិញរួចសុំម្ចាស់របស់អ្នកបន្ធូបន្ថយ ។ពេលនោះណាហ្គីបានក្រឡេកមើលទៅជីប៉្ររ៉អ៊ីល បានធ្វើសញ្ញាយល់ព្រមបើណាហ្គីមូហាំម៉ាត់ចង់ទៅ" ។ ពេលណាហ្គីទៅជួបទ្រង់អល់ឡោះបានបញ្ចុះអោយដប់ទៀត។ នៅពេលត្រឡប់មកវិញជួបមូសាមូសាក៏បានប្រាប់ថា៖ ប្រជាជនរបស់អ្នកគ្មានលទ្ធភាពធ្វើបានទេអ្នកត្រូវវិលទៅវិញរួចសុំម្ចាស់របស់អ្នកបន្ធូបន្ថយ។ ណាហ្គីមូហាំម៉ាត់បានធ្វើតាមរហូតនៅសល់៥ពេលក្នុងមួយថ្ងៃមួយយប់តែមូសានៅតែប្រើអោយណាហ្គីមូហាំម៉ាត់ទៅសុំពីអល់ឡោះអោយបន្ធូបន្ថយទៀតព្រោះប្រជាជនរបស់អ្នកមិនអាចធ្វើបានទេ។ ណាហ្គីមូហាំម៉ាត់បានតបវិញថា៖ " ខ្ញុំខ្មាស់ម្ចាស់របស់ខ្ញុំណាស់ខ្ញុំព្រមទទួលយកនិងធ្វើតាមបទបញ្ជារបស់ទ្រង់ហើយ" ។ណាហ្គីបាន

---

*១-ប៉ៃតុលម៉ាក់មូរ ៖ឈ្មោះទីកន្លែងដែលពួកទេវៈបានចូលជារៀងរាល់ថ្ងៃ។*
*២-ស៊ិតរ៉ទុលមុនតើហ៊ើ៖ឈ្មោះដើមឈើម្យ៉ាងនៅក្នុងឋានសួគ៌នៅផ្នែកខាងស្ដាំនៃអារ៉ស្វរបស់អល់ឡោះ។*

វិលមកម៉ាក្កះវិញក្នុងយប់ដដែលនោះ ។ពេលព្រឹកឡើងលោកបានប្រាប់រឿងនេះដល់ក្រុមរបស់លោកពីអ្វីដែលអល់ឡោះបានអោយលោកឃើញ ពេលនោះមានអ្នកសើចចំអកនិងបង្កើនការភូតកុហក់លើណាហ្ពីថែមទៀត ។ មានអារ៉ាប់គូរ៉ៃស្សជាច្រើនបាននាំគ្នាទៅជួបអាហ្ពូហ្ពើកើរ ដើម្បីប្រាប់រឿងនេះព្រមទាំងបញ្ឈឺចិត្តដល់លោកក្នុងនាមជាមិត្តភក្តិរបស់មូហាំម៉ាត់ថា : មូហាំម៉ាត់បានអះអាងថាខ្លួនលោកត្រូវបានគេនាំទៅហ្ពៃទុលមឹកទិស និងបានបន្តដំណើររហូតដល់ជួបអល់ឡោះជាម្ចាស់នៅស៊ិត៌រ៉ទុលមុនតើហ៊ើនិងបានត្រឡប់មកវិញមុនពេលស៊ូហ្ពុះ[1] តើអាហ្ពូហ្ពើកើរជឿដែរឬ? អាហ្ពូហ្ពើកើរបានសួរវិញថាៈតើមូហាំម៉ាត់និយាយដូចនេះមែនឬ? បើលោកនិយាយមែនគឺខ្ញុំជឿ ហើយជឿរហូតវ៉ាហ៊ីដែលអល់ឡោះបញ្ជូនមកពីលើមេឃមកអោយលោកក្នុងថេរៈវេលាលឿនបំផុត ។ ការជឿយ៉ាងពិតប្រាដករបស់អាហ្ពូហ្ពើកើរនេះហើយធ្វើអោយរ៉ស៊ូលុលឡោះដាក់ងារលោកថាៈ " អាហ្ពូហ្ពើកើរអាស្សិុតឌីក" ។

❁❁❁

## ការសច្ចានៅអាគហ្ពះលើកទី១

នៅឆ្នាំទី១២ បន្ទាប់ពីតែងតាំងជាណាហ្ពី មានបុរសចំនួន ១២ នាក់មកពីទីក្រុងម៉ាឌីណះក្នុងនោះមកពីអំបូរអាល់ខស្សរ៉ច់១០នាក់ និងអំបូរអៅស៏២នាក់ ។ពួកគេបានមកជួបនឹងមូហាំម៉ាត់នៅអាកហ្ពះ[2] នៅតំបន់មីណា ។ ណាហ្ពីបានបង្រៀនដល់ពួកគេនូវច្បាប់អ៊ីស្លាម ហើយលោកក៏បានមាន

---

*១ -ស៊ូហ្ពុះ : ពេលព្រឹកមុនថ្ងៃរះ*

*២-អាកហ្ពះ :ឈ្មោះទីកន្លែងមួយនៅតំបន់មីណានៃប្រទេសអារាប៊ីសាអូឌីដ ។*



ប្រសាសន៏ទៅកាន់បុរសទាំងនោះថា "សូមពួកអ្នកធ្វើការសច្ចាជាមួយខ្ញុំថាពួកអ្នកនឹងមិនត្រូវធ្វើស្ហ៊ីរិកចំពោះអល់ឡោះនូវប្រការអ្វីមួយឡើយហើយមិនធ្វើការលួចប្លន់មិនរួមភេទដោយខុសច្បាប់ មិនសំលាប់កូនៗរបស់ពួកអ្នកមិនពោលពាក្យភូតកុហកនិងមិនត្រូវធ្វើការប្រឆាំងរាល់ការបង្គាប់ប្រើរបស់ខ្ញុំទៅលើផ្លូវល្អឡើយ ។ជនណាបានអនុវត្តនូវប្រការខាងលើរូបគេនឹងទទួលផលបុណ្យពីអល់ឡោះ ហើយជនណាបានប្រព្រឹត្តល្មើសនឹងពាក្យសច្ចានេះរួចទទួលរងនូវទណ្ឌកម្មនៅលើលោកិយនោះ វាជាការពិន័យចំពោះគេសំរាប់ទង្វើខុសឆ្គងរបស់គេ ។ បុរសទាំង១២រូបក៏បានធ្វើការសច្ចាលើប្រការដែលបានរៀបរាប់ខាងលើ ។

❁❁❁

## ការសច្ចានៅអាគហ្ពះលើកទី២

នៅរដូវហាជ្ជឆ្នាំទី១៣បន្ទាប់ពីក្លាយជាណាហ្ពី មានអ្នកនៅយ៉ាសរិបជាច្រើនទាំងជនមូស្លីមនិងពួកមូសរិគីនមកជួបណាហ្ពី ។ ប្រជាជនមូស្លីមបានធ្វើការសំរេចថានឹងមិនបណ្តោយទុកអោយរ៉ស៊ូលុលឡោះនៅបន្តដើរអំពាវនាវតាមដងភ្នំដែលត្រូវគេបណ្តេញ និងត្រូវទទួលរងនូវការបំភិតបំភ័យទៀតឡើយ ។ពួកគេបានស្ងាត់ទៅជួបនឹងលោកដោយស្ងាត់កំបាំងនិងបានឯកភាពគ្នាថានឹងធ្វើការជួបជុំមួយនៅអំឡុងថ្ងៃតាស្ហរិក( ថ្ងៃទី១០ខែហ្ស៊ុលហាជ្ជះ ) នាពេលរាត្រីក្នុងជ្រលងភ្នំនៅជិតបង្គោលធំ( យ៉ាំរ៉ទុលអាកហ្ពះ ) ។

លុះថ្ងៃសន្យាបានមកដល់ពួកគេបានសំរាកនៅលំនៅរបស់ពួកគេជាមួយនឹងក្រុមរបស់ពួកគេ រហូតដល់រំលងមួយភាគបីនៃយប់ពួកគេចាប់ផ្តើមធ្វើ

ការលបចេញម្តងម្នាក់ឬពីរឬបីនាក់ម្តងរហូតជួបជុំគ្នានៅអាកហ្គះ ។នៅពេលនោះពួកគេមានបុរសចំនួន៧៣នាក់និងស្ត្រីចំនួន២នាក់ ។រ៉ស៊ូលុលឡោះបានមកជួបពួកគេរួមជាមួយនឹងមារបស់លោកឈ្មោះ**អាប់ហ្គើសកូនអាប់ឌុលមូតលលិប**ដែលកាលនោះមារបស់លោកនៅកាន់សាសនាក្រុមរបស់គាត់នៅឡើយ( សាសនាដូនតា) ប៉ុន្តែមារបស់លោកមកជាមួយពួកគេដើម្បីចូលរួមក្នុងកិច្ចការក្មួយរបស់គាត់និងដើម្បីអោយមានទំនុកចិត្តក្នុងកិច្ចការនេះ ។

អាប់ហ្គើសជាអ្នកផ្តើមនិយាយមុនគេ ដោយលោកបានពោលថា ជាការពិតរ៉ស៊ូលុលឡោះកំពុងស្ថិតក្នុងភាពថ្លៃថ្នូរក្នុងអំបូររបស់លោក និងកំពុងទទួលនូវការការពារនៅក្នុងស្រុករបស់លោក ។ ដូចនេះប្រសិនបើពួកអ្នកយល់ថាពួកអ្នកនឹងអនុវត្តនូវអ្វីដែលលោកបានអំពាវនាវពួកអ្នកនិងការពាររូបលោកអំពីពួកអ្នកប្រឆាំងនឹងលោកនោះពួកអ្នកទទួលយករូបលោកនិងទទួលអនុវត្តនូវកិច្ចសន្យានេះចុះ ។ បើពុំដូចនោះទេចូរពួកអ្នកបោះបង់រូបលោកចាប់ពីឥឡូវនេះចុះ ។ អ្នកតំណាងរបស់ពួកគេម្នាក់បានឆ្លើយតបថា: ពួកយើងសូមសំដែងនូវភក្តីភាពនិងជឿតាមលោកជានិច្ច ព្រមទាំងសុខចិត្តពលីជីវិតដើម្បីការពាររូបលោក ។ ដូចនេះសូមរ៉ស៊ូលុលឡោះអញ្ជើញមានប្រសាសន៍ចុះ ហើយសូមដាក់លក្ខខណ្ឌមកលើពួកយើង តាមតែអ្វីដែលលោកយល់ឃើញ ។ នៅពេលនោះរ៉ស៊ូលុលឡោះបានសូត្រគម្ពីរអាល់គួរអាននិងបួងសួងអល់ឡោះ ហើយបានពន្យល់ណែនាំអំពីអ៊ីស្លាមព្រមទាំងដាក់លក្ខខណ្ឌចំពោះពួកគេថា:

- ពួកគេត្រូវតែធ្វើការគោរពចំពោះអល់ឡោះតែមួយគត់ និងមិនត្រូវធ្វើ



ស្ទីរកចំពោះទ្រង់នូវប្រការអ្វីមួយឡើយ ។
- ត្រូវស្តាប់និងគោរពតាមលោកគ្រប់កាលៈទេសៈ ។
- ត្រូវជួយផ្គត់ផ្គង់រវាងគ្នានិងគ្នា ទោះពេលមាន ឬពេលក្រីក្រ ។
- ត្រូវសហការអប់រំគ្នាទៅរកផ្លូវល្អ ជៀសវាងប្រការអាក្រក់ផ្សេងៗ ។
- គោរពតាមច្បាប់អល់ឡោះជាម្ចាស់ដោយមិនខ្លាចការរិះគន់ពីជនដទៃ ។
- ត្រូវការពាររ៉ស៊ូលុលឡោះដូចដែលពួកគេការពារខ្លួនប្រាណនិងក្រុមគ្រួសាររបស់ពួកគេ ហើយរ៉ស៊ូលុលឡោះសន្យាថា ពួកគេនឹងទទួលបាននូវឋានសួគ៌ ។

❁❁❁

## ការផ្លាស់ប្តូរទីលំនៅរបស់ពួកមូស្លីមទៅម៉ាឌីណះ

បន្ទាប់ពីការសច្ចានេះមកការផ្លាស់ទីលំនៅជាផ្លូវការនៃពួកមូស្លីមទៅទីក្រុងម៉ាឌីណះក៏បានចាប់ផ្តើមឡើង ។

អ្នកដែលធ្វើការផ្លាស់ទីលំនៅមុនគេបង្អស់គឺលោក**អាហ្គូសាឡើម៉ះ**ដែលជាស្វាមីរបស់**អ៊ុំមូសាឡើម៉ះ** ។ បន្ទាប់មកគឺលោក**អាមេរ្យកូនរ៉ហ្គីអះ** និងភរិយារបស់គាត់ឈ្មោះ**ឡៃឡើកូនហាសម៉ះ** និងលោក**អាប់ឌុលឡោះកូនអ៊ុំមូមិកទូម** ។

ក្រោយពីការសច្ចារួចមកពួកមូស្លីមក៏ធ្វើការផ្លាស់ទីលំនៅជាបន្តបន្ទាប់ ។ តែពួកគេធ្វើការផ្លាស់ទីលំនៅដោយស្ងាត់កំបាំងព្រោះខ្លាចពួកគូរ៉ស្ស ។

រហូតដល់ពេលអ៊្វម៉ើរ កូន ខត្តប ធ្វើការផ្លាស់ទីលំនៅគឺគាត់ធ្វើឡើងដោយចំហរ ។គាត់មិនបានលាក់លៀមអ្វីឡើយហើយថែមទាំងបានប្រកាសប្រាប់ដល់ពួកគូរ៉ៃស្សទៀតផង។ អ៊្វម៉ើរបានធ្វើដំណើរមកម៉ាឌីណះរួមជាមួយនឹងមិត្តភក្តិ ២០ នាក់ទៀតផង ហើយប្រជាជនមូស្លីមទាំងអស់ក៏បានធ្វើការផ្លាស់ទីលំនៅទៅកាន់ម៉ាឌីណះ ។

✍**សារៈសំខាន់នៃជំពូកនេះ**

នៅក្នុងជំពូកនេះបានបង្ហាញនូវសារៈសំខាន់យ៉ាងច្រើនក្នុងនោះមានដូចជាៈ

- ការសិក្សារគឺជាកាតព្វកិច្ចលើបុគ្គលគ្រប់រូប ។
- រ៉ស៊ូលមានភារកិច្ចអប់រំនិងផ្សព្វផ្សាយរាល់បទបញ្ញត្តិរបស់អល់ឡោះ។
- រាល់បទបញ្ញត្តិដែលរ៉ស៊ូលផ្សព្វផ្សាយគឺមកពីអល់ឡោះទាំងអស់ ។
- អល់ឡោះបញ្ចុះវ៉ាហ៊ីមកលើរ៉ស៊ូលចាប់ពីពេលលោកមានអាយុ៤០ឆ្នាំ។
- ចំនុចចាប់ផ្តើមនៃការអំពាវនាវគឺបង្ហាញមនុស្សអោយស្គាល់អល់ឡោះជាម្ចាស់គ្រប់គ្រងពិភពទាំងមូលហើយមិនប្រព្រឹត្តស្ហ៊ីរិកចំពោះទ្រង់ ។
- ត្រូវបង្ហាញនិងផ្សព្វផ្សាយអំពីអ៊ីស្លាមដល់មនុស្សលោកទូទៅ។
- ការអប់រំនិងការអំពាវនាវគួរតែចាប់ផ្តើមពីអ្នកដែលនៅជិតខ្លួនមុនសិន។
- ការអប់រំនិងការអំពាវនាវត្រូវតែមានភាពទន់ភ្លន់ ។
- អ្នកអប់រំនិងអំពាវនាវគេ ត្រូវតែមានចំណេះដឹងយ៉ាងពិតប្រាដក។
- ត្រូវប្រកាន់នូវក្រមសីលធម៌ សុជីវធម៌ សច្ចះធម៌ ។
- អ៊ីស្លាមជាសាសនាមិនបង្ខិតបង្ខំ ។



- រ៉ស៊ូលពុំមានសិទ្ធិអំណាចក្នុងការចង្អុលបង្ហាញបុគ្គលណាម្នាក់អោយដើរតាមមាគ៌ាអល់ឡោះតាមចិត្តលោកចង់ឡើយបើទោះជាសាច់ញាតិក៏ដោយ
- រ៉ស៊ូលនិងពួកអ្នកមានជំនឿគ្មានសិទ្ធិសុំការលើកលែងទោសដល់ជនគ្មានជំនឿឡើយ ។
- បង្ហាញពីការតស៊ូនិងការព្យាយាមរបស់រ៉ស៊ូលុលឡោះ និងបណ្តាមិត្តភក្តិរបស់លោកក្នុងការការពារសាសនាអ៊ីស្លាម។

# ជំពូកទី៣

## ការផ្លាស់ទីលំនៅរបស់ណាពី ﷺ

**ការចាកចេញរបស់ណាពីពីគេហដ្ឋាន**

រ៉ស៊ូលុលឡោះបានចាកចេញពីលំនៅដ្ឋានរបស់លោកខណៈពេលដែលពួកយុវជនគូរ៉ស្សនៅព័ទ្ធជុំវិញផ្ទះរបស់លោក( រង់ចាំចាប់និងសំលាប់លោកនៅពេលលោកចាកចេញពីផ្ទះ) ។ពេលលោកចាកចេញ លោកក៏បានយកដីរោយលើក្បាលរបស់ពួកគេ ។ អល់ឡោះបានបិទភ្នែករបស់ពួកគេមិនអោយមើលឃើញណាពី ។ លោកបានបន្តដំណើរឆ្ពោះទៅកាន់ផ្ទះអាប៊ូបាក្កើរ ។


រូងភ្នំសួរ

បន្ទាប់មកលោកទាំងពីរក៏បានចាកចេញពីទីលំនៅឆ្ពោះទៅកាន់ភ្នំមួយដែលគេហៅថា” ភ្នំសួរ” ។នៅពេលទៅដល់ភ្នំនោះអាប៊ូបាក្កើរបាននាំណាពីចូលទៅក្នុងរូងភ្នំនោះ ។ ពេលនោះអាប៊ូបាក្កើរបានចូលទៅក្នុងរូងភ្នំ នោះមុនក្រែងមានអ្វីដែលនាំអោយមានគ្រោះថ្នាក់ដល់ណាពី ។ ក្រោយ មកគាត់អោយណាពីចូល ។ ពួកគាត់ទាំងពីរបានស្នាក់នៅទីនោះរយៈពេលបីថ្ងៃ ។ ចំណែកពួកគូរ៉ស្សមានភាពច្របូកច្របល់ខណៈពេលដឹងថាណាពីបានចាកចេញពីលំនៅដ្ឋានបាត់ហើយនោះ ។ ទោះជាយ៉ាងណាពួកគេនៅតែស្វែងរកពតិមានរបស់ណាពីដោយដឹងថាលោកទៅដល់ជួរភ្នំដោយបានពង្រាយកំលាំងព័ទ្ធជុំវិញភ្នំ ។ មានកំលាំងមួយចំនួនបានទៅដល់មាត់រូងភ្នំ



តែពួកគេមើលអ្វីមិនឃើញនៅខាងក្នុងរូងភ្នំនោះឡើយ ។ ពួកអ្នកតាមរកទាំងឡាយបានវិលត្រឡប់ថយក្រោយវិញ នៅពេលជិតដល់កន្លែងលោកទាំងពីរបានលាក់ខ្លួនប្រមាណពីរបីជំហានប៉ុណ្ណោះ ។

**តាមផ្លូវទៅកាន់ម៉ាឌីណះ**

នៅពេលការដេញតាមរបស់ពួកគូរ៉ស្សបានស្ងាត់លោកក៏ចេញដំណើរទៅកាន់ក្រុងម៉ាឌីណះនៅពេលរាត្រីទីពីរនៃខែរ៉ប៊ីអុលអៅវ៉ាល់ឆ្នាំទី១ម.ស ។ ការចេញដំណើររបស់លោកទាំងពីរនោះមានអ្នកនាំផ្លូវគឺ**អាប់ឌុលឡោះកូនអូរ៉ៃគុត**និង**អាមៀរកូនហ្វូហៃរ៉ស់** ។ ពួកគេបាននាំផ្លូវទៅកាន់ឆ្នេរសមុទ្រទៅតាមផ្លូវដែលពុំធ្លាប់មានមនុស្សដើររហូតដល់ឆ្នេរសមុទ្រក្រហមហើយក៏បន្តដំណើរតាមផ្លូវដ៏ឆ្ងាយ ។ ការធ្វើដំណើររបស់ពួកគាត់បានជួបនូវព្រឹត្តិការណ៍ និងមនុស្សជាច្រើន ។

នៅថ្ងៃច័ន្ទទី៨ ខែ រ៉ប៊ីអុលអៅវ៉ាល់ ឆ្នាំទី ១៤ នៃការតែងតាំងជាណាពីដែលវាជាឆ្នាំទី១នៃម.ស ។ រ៉ស៊ូលុលឡោះបានចុះចតនៅកន្លែងមួយឈ្មោះ**គូបាក** ។ប្រជាជននៅក្រុងម៉ាឌីណះខណៈពេលដែលពួកគេបានលឺចំពោះការចាកចេញរបស់ណាពីពួកគេក៏បានចេញទទួលស្វាគមន៏លោកនិងចាត់ជាថ្ងៃដ៏ប្រពៃដែលពួកគេទន្ទឹងរង់ចាំជាយូរមកហើយនោះ ។ការស្នាក់នៅរបស់ពួកគាត់នៅគូបាកចំនួន៤ថ្ងៃ ។ នៅថ្ងៃសុក្រលោកក៏បានចាកចេញ ហើយមកសឡាហ៏ជុមអះ[១] នៅជាមួយអំបូរ**សាលិមកូនអៅហ្វ៏**ដែលបានមកជួបជុំគ្នានៅក្នុងជ្រលងអូរដែលមានបុរសចំនួនប្រមាណ១០០នាក់ ។ ក្រោយមកក៏

*១-សឡាហ៏ជុមអះ : សឡាហ៏នៅថ្ងៃសុក្រ ពេលថ្ងៃត្រង់ ។*

បានធ្វើដំណើរទៅកាន់ម៉ាឌីណះ ដោយមានមនុស្សជាច្រើនចេញមកទទួលលោកដោយបញ្ចេញសូរសំលេងនៃការកោតសសើរនិងការលើកដំកើងដល់រូបលោក។ ប៉ុន្មានថ្ងៃក្រោយមកក៏មានមនុស្សជាច្រើនអ្នកទៀតបានចាកចេញមកតាមក្រោយណាប៊ីជាបន្តបន្ទាប់។

❁❁❁

## កិច្ចការនិងការកសាងនៅក្រុងម៉ាឌីណះ

បន្ទាប់ពីណាប៊ីﷺ បានផ្លាស់មកនៅម៉ាឌីណះ លោកបានរៀបចំទីនោះអោយបានល្អនិងធ្វើការសាងសង់ជាបន្តបន្ទាប់។

### ១-ការកសាងម៉ាស្ជិតណាប៊ី

ដំបូងបំផុតដែលលោកបានឈានមកដល់ទីនេះគឺកសាងម៉ាស្ជិតណាប៊ី ដែលស្ថិតនៅទីកន្លែងដែលសត្វអូដ្ឋបានលុតជង្គង់ ហើយដីនេះលោកបានទិញពីក្មេងកំព្រាពីរនាក់ដែលជាអ្នកគ្រប់គ្រងដីនេះ។ការកសាងម៉ាស្ជិតនេះគឺធ្វើឡើងដោយដីភក់ ដើមល្មើ និងធាងល្មើ។នៅក្បែរនោះលោកបានសង់ផ្ទះពីរគឺមួយសំរាប់សៅឌះនិងមួយសំរាប់អាអ៊ីស្ហះ ។



ម៉ាស្ជិតណាប៊ី នាសត្តវត្សទី១៤

### ២-ការអាហ្សាន

បណ្តាជនមូស្លីមបានចាប់ផ្តើមចូលរួមសឡាហ៍ប្រាំពេលជាជើម៉ាអះ[១] តាមពេលវេលារបស់វា។ កាលដើមឡើយគេដឹងការចូលដល់ពេលសឡាហ៍

*១-សឡាហ៍ជើម៉ាអះ : ការថ្វាយបង្គំចំពោះអល់ឡោះរួមគ្នា ឬជាក្រុម ។*



ដោយការដុតភ្លើង ផ្លុំត្រែ ឬវាយស្គរ។ពេលនោះអាប់ឌុលឡោះកូនហ្សៃត បានសុបិន្តអំពីអាហ្សានហើយក៏បានប្រាប់ណាប៊ីពីបញ្ហានេះ។ លោកក៏មានប្រសាសន៍ថា:"វាជាការពិត"។ ពេលនោះ លោកក៏បានប្រើអោយប៊ីឡាលចាប់ផ្តើមអាហ្សានតាំងពីពេលនោះមក ។

### ៣-ការបង្រួបបង្រួមរវាងក្រុមមូហ៊ើជីរីន[១]និងក្រុមអាន់សរ៍[២]

ណាប៊ីបានបង្រួបបង្រួមរវាងក្រុមមូហ៊ើជីរីន និងក្រុមអាន់សរ៍អោយក្លាយជាភាតរភាពនឹងគ្នា ស្រឡាញ់រាប់អានគ្នា ជួយគ្នាទៅវិញទៅមក។

### ៤-ការស្ថាបនាសង្គមអ៊ីស្លាមនិងប្រជាជនអ៊ីស្លាម

រ៉ស៊ូលុលឡោះបានចេញបទបញ្ជាដូចខាងក្រោម :

- ប្រជាជនទាំងអស់ទាំងពួកគូរ៉ស្សនិងពួកម៉ាឌីណះជាប្រជាជាតិតែមួយ។
- ពិតណាស់ការបង់រំលោះរបស់ពួកគេ និងការសងឈ្លើយសឹករវាងអ្នកមានជំនឿនោះវានឹងប្រតិបត្តិតាមការកំណត់កន្លងមក។
- អ្នកមានជំនឿត្រូវតែប្រឆាំងអ្នកដែលរំលោភបំពាន ឬអ្នកប្រព្រឹត្តអំពើអយុត្តិធមិ ឬបំផ្លិចបំផ្លាញក្នុងចំណោមអ្នកមានជំនឿ ។
- ច្បាប់អល់ឡោះតែមួយគត់ធានាការការពារពួកគេអោយស្មើភាពគ្នា។
- ប្រសិនបើពួកអ្នកមានការខ្វែងយោបល់គ្នាពិតណាស់ត្រូវវិលត្រឡប់ទៅចំពោះអល់ឡោះនិងរ៉ស៊ូលរបស់ទ្រង់ ។

✲✲✲

*១-មូហ៊ើជីរីន :ប្រជាជនដែលបានផ្លាស់ទីលំនៅពីក្រុងម៉ាក្កះទៅរស់នៅម៉ាឌីណះ។*

*២-អាន់សរ៍ :ប្រជាជនដែលរស់នៅម៉ាឌីណះ។*

# សមរភូមិសំខាន់ៗមួយចំនួន

## ១-សមរភូមិហ្គាឌ័រ

ស្ថិតនៅទិសខាងលិចនៃទីក្រុងម៉ាឌីណះប្រមាណ ១៥០ គ.ម ។

**មូលហេតុៈ** រ៉ស៊ូលុលឡោះមានគោលបំណងកាត់ផ្តាច់ផ្លូវពួកជំនួញគូរ៉ស្ស ជាមួយប្រទេសស្វាម ដើម្បីអោយពួកគេមានភាពទន់ខ្សោយ។ រ៉ស៊ូលុលឡោះបានដឹងដំណឹងថាក្រុមជំនួញនេះដឹកនាំដោយអាហ្គួសាហ្វយ៉ានចេញពីប្រទេសស្វាមដោយដឹកជញ្ជូននូវទ្រព្យសម្បត្តិយ៉ាងច្រើន ហើយមានអ្នកការពារប្រមាណ៣០ឬ៤០នាក់។ រ៉ស៊ូលុលឡោះបានចាកចេញពីម៉ាឌីណះរួមជាមួយនិងមនុស្ស៣១៤នាក់ ដែលមានយានជំនិះសត្វអូដ្ឋចំនួន ៧០ ក្បាល និងសត្វសេះ ២ ក្បាល ។

នៅពេលនោះអាហ្គួសាហ្វយ៉ានដឹងអំពីការចេញដំណើររបស់មូស្លីមពួកគេក៏ប្តូរផ្លូវដោយឆ្ពោះទៅតាមឆ្នេរសមុទ្រវិញហើយគេបានបញ្ជូន**ដាមដាមកូនអាំរូ**ទៅជូនដំណឹងដល់ពួកគូរ៉ស្ស ដើម្បីសុំជំនួយពីពួកគេការពារក្រុមជំនួញនិងមនុស្សរបស់ពួកគេ។ ពេលនោះពួកគូរ៉ស្ស បានប្រមូលកំលាំងទ័ពបានចំនួន១០០០នាក់និងសត្វអូដ្ឋចំនួន៧០០ក្បាលនិងសត្វសេះចំនួន ១០០ ក្បាល។ ក្រោយមកអាហ្គួសាហ្វយ៉ានបានបញ្ជូនដំណឹងទៅប្រាប់ពួកគេម្តងទៀតថា ពិតណាស់គាត់បាននាំក្រុមគេចផុតទៅហើយ តែពួកគូរ៉ស្សនៅតែបន្តដំណើររបស់ពួកគេរហូតដល់**ហ្គាឌ័រ**។

នៅពេលរ៉ស៊ូលុលឡោះបានដឹងដំណឹងពីការចាកចេញរបស់ពួកគូរ៉ស្សដើម្បី



ធ្វើសង្គ្រាម លោកក៏បានណែនាំមិត្តភក្តិរបស់លោកអោយចេញទៅធ្វើសង្គ្រាមដោយរូបលោកមិនបានទៅជាមួយទេ។

**កាលបរិច្ឆេទនៃសង្គ្រាមៈ**គឺនៅថ្ងៃ សុក្រទី១៧ខែ រ៉ម៉ាដនឆ្នាំទី២ ម.ស។

**លទ្ធផលនៃសង្គ្រាម :**

- មូស្លីមទទួលបានជោគជ័យហើយពួកមូសរិគីនទទួលបរាជ័យ ។
- មូស្លីមទទួលមរណៈភាពចំនួន ១៤ នាក់ ។
- មូស្លីមទទួលនូវជ័យភ័ណ្ឌយ៉ាងច្រើន។
- សំលាប់ពួកមូសរិគីនចំនួន៧០នាក់ និងចាប់ឈ្លើយសឹកបានចំនួន ៧០នាក់ ។
- ពួកមូសរិគីនដឹងយ៉ាងច្បាស់ចំពោះភាពខ្លាំងរបស់មូស្លីម ។

## ២-សមរភូមិអ៊ូហ៊ុត



ភ្នំអូហ៊ុតមានទីតាំងនៅទិសខាងជើងនៃក្រុងម៉ាឌីណះ។មានចំងាយប្រមាណ ៥ ម៉ាយ ពីម៉ាស្ជិតណាហ្វី (ក្នុង១ម៉ាយ= ១.៦០៨គ.ម)។

**មូលហេតុៈ** ពួកគូរ៉ស្សមានគោលបំណងសងសឹកដោយពួកគេបានចាញ់នៅសមរភូមិហ្គាឌ័រ។ពួកគេបានប្រមូលកំលាំងទ័ពបានចំនួន៣០០០នាក់ហើយបានចាកចេញពីក្រុងម៉ាក្កះរហូតដល់ក្រុងម៉ាឌីណះ។នៅពេលរ៉ស៊ូលុលឡោះ

បានលឺដំណឹងនេះក៏ចង្អុលបង្ហាញអោយមិត្តភក្តិរបស់លោកអោយចេញទៅធ្វើសង្គ្រាមនៅតំបន់ **ភ្នំអ៊ូហ៊ុត** ដោយមានចំនួន ១000នាក់។

**កាលបរិច្ឆេទ**:កើតឡើងនៅថ្ងៃសៅរ៍ពាក់កណ្តាលខែសៅវ៉ាល់ឆ្នាំទី៣ម.ស

**លទ្ធផលនៃសង្គ្រាម :**

- មូស្លីមទទួលមរណៈភាពចំនួន៧0នាក់ក្នុងនោះមានមារបស់ណាហ្ពី ឈ្មោះ**ហាំហ្ស៊ះកូនអាប់ឌុលមូតល់លិប** និង **ម៉ាសអាប់កូនអូម៉ៃរ៍**។
- រ៉សូ៊លុលឡោះទទួលរងរបួស ។
- ពួកមូសរិគីនស្លាប់ចំនួន ២២ នាក់។



**៣-សមរភូមិអះហ្សាប**

មានការចូលរួមពីសំណាក់កុលសម្ព័ន្ធជាច្រើនអំពីពួកមូសរិគីន និងពួកយ៉ាហ៊ូឌីដើម្បីធ្វើសង្គ្រាមជាមួយពួកមូស្លីម ។ចំនួនមនុស្សទាំងពីរក្រុមគឺមានបុរសចំនួន១0000នាក់ ដោយមូស្លីមមានចំនួន ៣000 នាក់ ។

**លទ្ធផលនៃសង្គ្រាម**:

**ការបរាជ័យរបស់ពួកមូសរិគីន**:អល់ឡោះបានទំលាក់ខ្យល់យ៉ាងខ្លាំងទៅលើពួកមូសរិគីនអោយប៉ើងនូវជំរករបស់ពួកគេ ធ្វើអោយពួកគេបានបែកខ្ញែកគ្នា និងវិលត្រឡប់ទៅលំនៅដ្ឋានរបស់ពួកគេវិញ។

**៤-សមរភូមិខៃហ្ពើរ**

**ខៃហ្ពើរ** ជាតំបន់កសិកម្មស្ថិតនៅខាងជើងក្រុងម៉ាឌីណះមានចំងាយប្រមាណ ១៦៥ គ.ម។



**មូលហេតុ**:បន្ទាប់ពីសង្គ្រាមហ៊ូឌៃហ្ពីយ៉ះរ៉សូ៊លុលឡោះមើលឃើញនូវពេលវេលាសមរម្យសំរាប់ធ្វើសង្គ្រាមជាមួយពួកយ៉ាហ៊ូឌី ពីព្រោះពួកវាសំដែងចេញនូវភាពជាសត្រូវចំពោះអ៊ីស្លាម ដោយពួកគេក្បត់កិច្ចសន្យាសន្តិភាពជាមួយគ្នា មិនតែប៉ុណ្ណោះពួកនេះថែមទាំងរួមគំនិតជាមួយពួកអះហ្សាបក្នុងការធ្វើសង្គ្រាមប្រឆាំងមូស្លីមទៀតផង។

**ការរំដោះខៃហ្ពើរ** : រ៉សូ៊លុលឡោះបានធ្វើដំណើរទៅជួបពួកគេនៅក្នុងខែមូហើរ៉មឆ្នាំទី៧ម.ស ។ពួកយ៉ាហ៊ូឌីបានចេញទៅកសិដ្ឋានរបស់ពួកគេហើយនៅពេលពួកគេបានឃើញពួកមូស្លីម ពួកគេក៏រត់ត្រឡប់ទៅលំនៅដ្ឋានរបស់ពួកគេវិញ។ រ៉សូ៊លុលឡោះបានបិទច្រកចេញចូលរបស់ពួកគេហើយសំលាប់ពួកគេយ៉ាងខ្លាំងរហូតដល់ពួកមូស្លីមទទួលបានជោគជ័យ។

**លទ្ធផលនៃសង្គ្រាម :**

- មូស្លីមត្រូវបានសំលាប់ចំនួន ២0នាក់។
- ពួកយ៉ាហ៊ូឌីត្រូវបានសំលាប់ចំនួន ៩៣ នាក់។
- មូស្លីមទទួលបាននូវជ័យភ័ណ្ឌយ៉ាងច្រើនអនេក ។

**៥-ការរំដោះទីក្រុងម៉ាក្កះ**

នៅឆ្នាំទី៨ម.សពួកគូរ៉ស្សបានបដិសេធលើការឯកភាពគ្នានៅហ៊ូឌៃហ្ពីយ៉ះ។ **អាំរូកូនសើលិមខាហ្សាអ៊ី** បានធ្វើដំណើរឆ្ពោះទៅកាន់ម៉ាឌីណះ ហើយផ្តល់ដំណឹងដល់ណាហ្ពីថា:"ពិតណាស់ពួកគូរ៉ស្សបានក្បត់កិច្ចសន្យា"។ រ៉សូ៊លុលឡោះបានប្រើអោយមូស្លីមរៀបចំខ្លួនដោយសំងាត់ ដើម្បីកុំឱ្យពួកគូរ៉ស្សដឹង។

គេបានប្រមូលផ្តុំគ្នាមានចំនួន១០០០០នាក់។ រ៉ស៊ូលុលឡោះ បាននាំពួកគេចេញនៅក្នុងខែរ៉មាជននឆ្នាំទី៨ម.ស រហូតជិតដល់ក្រុងម៉ាក្កះ។

☪ - **ការចូលក្រុងម៉ាក្កះរបស់ពួកមូស្លីមៈ**

រ៉ស៊ូលុលឡោះបានបែងចែកកំលាំងជា ៤ ក្រុម ៖

១- ក្រុមទីមួយ ដឹកនាំដោយ **ហ្សៃរ៍ កូន អៅវ៉ាម** នាំកំលាំងចូលតាមផ្នែកខាងលើ ។

២- ក្រុមទីពីរ ដឹកនាំដោយ **ខលីដ កូន វ៉ាលីដ** នាំកំលាំងចូលតាមផ្នែកខាងក្រោមម៉ាក្កះ។

៣- ក្រុមទីបី ដឹកនាំដោយ**អាហ្គី អូហ្ពៃឌះ កូន អាល់យ៉ារ៉ហ៍** នាំកំលាំង ចូលតាមច្រកខាងកើត។

៤- ក្រុមទីបួន ដឹកនាំដោយ**កៃស៍កូនសាអាត់**នាំកំលាំងចូលតាមច្រកផ្សេងទៀត ។ពួកគេបាននាំគ្នាចូលទាំងអស់សំដៅទៅម៉ាក្កះដោយគ្មានការតទល់គ្នាឡើយ ។ មូស្លីមបានរំដោះម៉ាក្កះបានជោគជ័យនិងពេញលេញ ។

❁❁❁



# មរណៈភាពរបស់ណាហ្គី ﷺ

## ការចាប់ផ្តើមមានជំងឺ

នៅថ្ងៃទី២៨ខែសហ្វើរឆ្នាំទី១១ម.ស ណាហ្គីបានទៅមើលផ្នូរនៅឯហ្ពៃគាក [១] ។ នៅពេលវិលមកវិញដល់ពាក់កណ្តាលផ្លូវ លោកក៏ចាប់ផ្តើមឈឺក្បាលនិងឡើងកំដៅយ៉ាងខ្លាំង។ លោកបានសឡាហ៍រួមជាមួយប្រជាជនខណៈពេលលោកឈឺរយៈពេល១១ថ្ងៃ ។ បើសរុបទាំងអស់ថ្ងៃដែលលោកឈឺប្រមាណ១៣ ឬ ១៤ ថ្ងៃ ។ជំងឺរបស់លោកកាន់តែធ្ងន់ធ្ងរទៅៗ។ លោកបានសំរាកនៅជាមួយអាអ៊ីស្ហះ នាសប្តាហ៍ចុងក្រោយនៃជីវិតរបស់លោក។ ដង្ហើមចុងក្រោយរបស់លោកបានមកដល់អាអ៊ីស្ហះបានផ្អែកលោកមកលើខ្លួនរបស់គាត់ហើយក៏ត្រូវបញ្ចប់បន្ទាប់ពីពេលនោះមក។

ព្រឹត្តិការណ៍នេះបានកើតឡើងនៅមុនថ្ងៃត្រង់ក្នុងថ្ងៃច័ន្ទ១២កើត ខែរ៉ហ្គីអ៊ុលអៅវ៉ាល់ ឆ្នាំទី១១ ម.ស ។លោកមានអាយុ គម្រប់៦០ ឆ្នាំ និងបួនថ្ងៃ ។

❁❁

---

*១ - ហ្ពៃគាក :ទីកន្លែងបញ្ចុះសពជនមូស្លីមមានទីតាំងនៅខាងកើតម៉ាស្ជិតណាហ្គីនៅក្រុងម៉ាឌីណះ។*

# គ្រួមគ្រួសាររបស់ណាប៊្ី ﷺ

ពិតណាស់សំរាប់ណាប៊្ីនៅឆាកជីវិតរបស់លោកមានភរិយាចំនួន ១១នាក់ឬ១២នាក់។ ក្នុងនោះមាន៩នាក់ ដែលបានរស់នៅជាមួយលោករហូតដល់ដំណាក់កាលចុងក្រោយនៃជីវិតរបស់លោកហើយ២ ឬ ៣នាក់ផ្សេងនោះគឺទទួលមរណៈភាពមុនលោក។ ខាងក្រោមនេះគឺបណ្ដាភរិយារបស់លោក :

**១-អ៊ុំមុលមុមីនីន ខឌីជះ កូនស្រី ខូវៃលិត :**

ណាប៊្ីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីខណះលោកស្រីមានអាយុ៤០ឆ្នាំហើយរូបលោកមានអាយុ២៥ឆ្នាំ។ លោកពុំបានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីណាម្នាក់ក្នុងអំឡុងពេលដែលលោកស្រីនៅរស់ឡើយ។ លោកស្រីទទួលមរណៈភាពនៅក្រុងម៉ាក្កះក្នុងខែរ៉មាំដន ឆ្នាំទី១០ នៃការតែងតាំងជារ៉ស៊ូល។ លោកស្រីមានអាយុ ៦៥ ឆ្នាំ ។

**២- អ៊ុំមុលមុមីនីនសៅឌះ កូនស្រី ហ្សំអះ :**

ណាប៊្ីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅក្នុងខែ សៅវ៉ាល់ ឆ្នាំទី ១០ នៃការតែងតាំងលោកជារ៉ស៊ូល បន្ទាប់ពីមរណៈភាពរបស់លោកស្រីខឌីជះប្រហែលមួយខែ។ លោកស្រីទទួលមរណៈភាពនៅម៉ាឌីណះខែសៅវ៉ាល់ ឆ្នាំ ៥៤ ម.ស ។

**៣- អ៊ុំមុលមុមីនីន អាអ៊ីស្ហះ កូនលោក អាហ្ពូហ្គើកើរ :**

ណាប៊្ីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅក្នុងខែ សៅវ៉ាល់



ឆ្នាំទី១១ នៃការតែងតាំងជារ៉ស៊ូល បន្ទាប់ពីលោកស្រីសៅឌះ។ កាលនោះលោកស្រីមានអាយុ៦ឆ្នាំ ហើយលោកចូលទៅរស់នៅជាមួយលោកស្រីនៅខែសៅវ៉ាល់បន្ទាប់ពីធ្វើការផ្លាស់ទីលំនៅទៅកាន់ក្រុងម៉ាឌីណះបានប្រហែល ៧ខែដោយលោកស្រីមានអាយុគម្រប់៩ឆ្នាំ។ លោកស្រីទទួលមរណៈភាពនៅថ្ងៃទី ១៧ ខែ រ៉មាំដន ឆ្នាំ ៥៧ ម.ស ឬ ៥៨ ម.ស ។

**៤- អ៊ុំមុលមុមីនីន ហាហ្វសោះ កូនស្រី អ៊ូម៉ើរ កូន ខត្តប :**

ណាប៊្ីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅក្នុងខែស្ហាក់ហ្គើនឆ្នាំទី៣ម.ស ។ លោកស្រីទទួលមរណៈភាពនៅក្រុងម៉ាឌីណះខែសាក់ហ្គើនឆ្នាំ ៤៥ ម.ស ។ លោកស្រីមានអាយុ ៦០ ឆ្នាំ ។

**៥- អ៊ុំមុលមុមីនីន ហ្សៃនាប់ កូនស្រី ខូហ្សៃម៉ះ ហ៊ីឡាលីយ៉ះ :**

ណាប៊្ីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅឆ្នាំទី៤ម.ស។ លោកស្រីទទួលមរណៈភាពនៅចុងខែរ៉ហ្ប៊ៀកអាល់អាខ្សេរ ឆ្នាំទី៤ម.ស ។

**៦- អ៊ុំមុលមុមីនីន អ៊ុំមូសិលម៉ះ ហ៊ិនឌ៏ កូនស្រី អាហ្ពីអ៊ូមៃយ៉ះ :**

ណាប៊្ីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅខែស្ហៅវ៉ាល់ឆ្នាំទី ៤ម.សហើយលោកស្រីទទួលមរណៈភាពនៅ ឆ្នាំ ៥៩ ឬ ៦០ ។ លោកស្រីមានអាយុ ៨៤ឆ្នាំ ។

**៧- អ៊ុំមុលមុមីនីន ហ្សៃនាប់ កូនស្រី យូសស៊ីន កូនរីអាប :**

ណាប៊្ីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅខែហ៊្សុលកក់ឌះឆ្នាំទី៥។ លោកស្រីទទួលមរណៈភាពនៅឆ្នាំទី២០ម.ស ដោយលោកស្រីមាន អាយុ ៥៣ ឆ្នាំ ។

**៨- អ៊ុំមុលមុមីនីន យូវៃរីយ៉ះ កូនស្រី ហារីស :**

នៅឆ្នាំទី៦ម.សលោកស្រីត្រូវបានដោះលែងពីចំណាប់ខ្មាំងដោយមានចុះកិច្ចសន្យាក្រោយមកណាហ្ពីក៏បញ្ចប់កិច្ចសន្យានោះ រួចក៏រៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅក្នុងឆ្នាំនោះដែរ ។ លោកស្រីទទួលមរណៈភាពនៅខែ រ៉េហ្បៀកអ៊ិលអៅវ៉ាល់ ឆ្នាំ ៥៦ម.ស ដោយលោកស្រីមានអាយុ ៦៥ ឆ្នាំ ។

**៩- អ៊ុំមុលមុមីនីន អ៊ុំមូហាហ្ពីហ្ពះ រ៉មឡះ កូនស្រី អាហ្ពីសាហ្វយ៉ាន :**

រ៉ស៊ូលុលឡោះបានបញ្ជូនអាំរូ កូន អូមៃយ៉ះអោយនាំសារលិខិតទៅកាន់អាន់ណាយើស៊ី សុំអោយលោករៀបការលោកស្រី **អ៊ុំមូហាហ្ពីហ្ពះ** ជាមួយណាហ្ពី។ ពេលនោះអាន់ណាយើស៊ីក៏យល់ព្រមតាមសំណើរនោះ។ លោកបានចូលទៅរស់នៅជាមួយលោកស្រីខណៈពេលលោកបានវិលត្រឡប់ពីសមរភូមិ ខៃហ្ពើរ ឆ្នាំទី៧ ម.ស ។លោកស្រីទទួលមរណៈភាពនៅឆ្នាំ៤២ម.ស ។

**១០- អ៊ុំមុលមុមីនីន សហ្វីយ៉ះ កូនស្រី ហ៊ូយៃ :**

លោកស្រីត្រូវបានរៀបអាពាហ៍ពិពាហ៍ជាមួយណាហ្ពី នៅក្រោយរំដោះខៃហ្ពើរ ឆ្នាំទី ៧ ម.ស ។លោកស្រីទទួលមរណៈភាពនៅឆ្នាំ ៥0 ម.ស ។

**១១- អ៊ុំមុលមុមីនីន មៃម៉ូណះ កូនស្រី ហារីស ហ៊ីឡាលីយ៉ះ :**

ណាហ្ពីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រីនៅខែហ្ស៊ុលកអ៊ីឌះ ឆ្នាំទី៧ ហើយលោកស្រីទទួលមរណៈភាពនៅឆ្នាំ ៦១ ម.ស ។

✍ ភរិយា១១នាក់ខាងលើណាហ្ពីបានរៀបអាពាហ៍ពិពាហ៍ជាមួយដោយពុំមានទស្សនៈនៃសេចក្តីរាយការណ៍ណាមួយមានការខ្វែងគ្នាឡើយ ។ តែ



មានការខ្វែងយោបល់គ្នាចំពោះស្ត្រីម្នាក់ឈ្មោះ **រ៉ៃហាណាស់កូនស្រីហ៊ែរត** ថាតើលោកស្រីស្ថិតក្នុងចំណោមភរិយារបស់ណាហ្ពីឬក៏ជាស្រីបំរើ ។

ចំពោះស្ត្រីម្នាក់ទៀតឈ្មោះ **ម៉ារីយ៉ះ កប់ទីយ៉ះ** គឺជាស្រីបំរើផ្ទាល់របស់ណាហ្ពី ។លោកស្រីទទួលមរណៈភាពនៅខែមូហើរ៉មឆ្នាំ ១៦ ម.ស ។

✍ **សារៈសំខាន់ក្នុងជំពូកនេះ**

**នៅក្នុងជំពូកនេះបានបង្ហាញនូវសារៈសំខាន់យ៉ាងច្រើនក្នុងនោះមានដូចជាៈ**

- អ៊ីស្លាមអនុញ្ញាតអោយធ្វើការផ្លាស់ទីលំនៅខណៈពេលមានការធ្វើទុក្ខបុកម្នេញនិងបិទសិទ្ធិសេរីភាពដល់ខ្លួននោះ។
- បង្ហាញពីការតស៊ូនិងការអត់ធ្មត់យ៉ាងមោះមុតរបស់រ៉ស៊ូល ។
- ម៉ាស្ជិតជាទីកន្លែងគោរពប្រតិបត្តិចំពោះអល់ឡោះនិងជាទីកន្លែងសំរាប់សិក្សា ។
- មូហាំម៉ាត់ ជាបរមគ្រូនិងជាមគ្គុទេសរបស់មនុស្សលោកទាំងអស់ ។
- ច្បាប់អនុញ្ញាតឱ្យអាហ្សានសំរាប់ជាសញ្ញាប្រាប់ពីពេលវេលាសឡាហ៍ ។
- បង្ហាញពីការបង្រួបបង្រួម និង សាមគ្គីភាពក្នុងសង្គម ។
- បង្ហាញពីការស្ថាបនានិងការកសាងក្នុងសង្គម ។
- បង្ហាញពីភាពក្លាហាន និងការតស៊ូរបស់អ៊ីស្លាមគ្រប់កាលៈទេសៈ ។
- ច្បាប់មួយចំនួនគឺសំរាប់តែរ៉ស៊ូលតែមិនមែនសំរាប់មនុស្សទូទៅអនុវត្តឡើយ ។
- ត្រូវប្រកាន់តាមគម្ពីរគួរអាន និងមាគ៌ាណាហ្ពីមូហាំម៉ាត់ ។

❁❁❁

យើងខ្ញុំសង្ឃឹមថាការស្វែងយល់ក្នុងអត្ថបទនេះពិតជានាំមកនូវចំនេះដឹងដ៏ប្រសើរបន្ថែមទៀតសំរាប់អស់លោកអ្នក ។ក្នុងនាមយើងខ្ញុំអ្នកប្រែសំរួលជាភាសាខ្មែរសូមរង់ចាំទទួលការរិះគន់ស្ថាបនាពីសំនាក់មិត្តអ្នកអានជានិច្ច ។

យើងខ្ញុំសូមបួងសួងពីអល់ឡោះជាម្ចាស់ សូមទ្រង់មេត្តាប្រទានដល់ក្រុមយើងខ្ញុំ និងមិត្តអ្នកអានទាំងឡាយនូវការចង្អុលបង្ហាញទៅរកផ្លូវត្រូវ និង ភាពសុចរិតក្នុងលោកនិងបរលោក ។



## المصادر والمراجع


១- روضة الأنوار في سير النبي المختار صفى الرحمن المبار كفوري / دار السلام ، الرياض.

២- في ظلال السيرة النبوية علاء الدين آل رشي /دار الفكر ، دمشق - سورية

៣- المنهل العذب المنير في سيرة السراج المنير د/ وليد بن محمد العلي / مكتب الشؤون الفنية.

៤- مختصر سير الرسول شيخ السلام محمد عبد الوهاب / دار القلم.

៥- مختارات من السيرة النبوية علي بن مسلم الأحمدي الجامعة الإسلامية.


## ដកស្រង់ចេញពីសៀវភៅ


១-រ៉ាវដទុលអាន់វ៉ារ ហ្វីស៊ីរ៉ោះណាពី អាល់មោះតើរ សហ្វើ រ៉ស់ម៉ាន អាល់ម៉ាពើរកើហ្វូរីឌើរសាឡាម- រីយ៉ោដ.

២-ហ្វីហ្ស៊ីឡាលីស៊្សីរ៉ោះណាពើវីយ៉ះ អាឡើអាត់ឌីន អាលីរ៉ហ្ស៊ី ឌើរហ្វិករី ឌីមិស ស៊ីរី

៣-អាល់មិនហ៊ើល អាល់អិស្ប អាល់មូនៀរ ហ្វីស៊ីរ៉ោះអាស្ស៊ីរ៉ចអាល់មូនៀរ ដុកទ័រវ៉ាលិត ពិន មូហាំម៉ាត់ អាល់អាលី មឹកតាប់ស៊្សូអ៊្សូនហ្វាន្នីយ៉ះ ។

៤-មោះតើសើរ ស៊ីរ៉ោះរ៉ស៊ូល សៀហ្ខសើឡាម-មូហាំម៉ាត់អាប់ឌុលវ៉ាហ៊ើប-ឌើរកឡាំ.

៥-មោះតើរ៉តមីណិស៊្សីរ៉ោះអាន់ណាពើវីយ៉ះ អាលី ពិនមូស្លីម អាល់អះម៉ាត់ឌី-អាល់ជើមីអះ អាល់អ៊ីស្លាមីយ៉ះ. ។